ព្រះរាជាណាចក្រកម្ពុជា

ជាតិ - សាសនា - ព្រះមហាក្សត្រ

# លទ្ធផលបឋម
# អង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជា
# ឆ្នាំ ២០១៤

អនុវត្តដោយ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ
ដោយមានកិច្ចសហការបច្ចេកទេស និងថវិការពី
រដ្ឋាភិបាលជប៉ុន និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

ភ្នំពេញ កម្ពុជា
ខែកញ្ញា ឆ្នាំ ២០១៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ - សាសនា - ព្រះមហាក្សត្រ

NIS

# លទ្ធផលបឋម
# អង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជា
# ឆ្នាំ២០១៤

អនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ
ដោយមានកិច្ចសហការបច្ចេកទេស និង ថវិកាពី
រដ្ឋាភិបាលប្រទេសជប៉ុន និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

ភ្នំពេញ កម្ពុជា
ខែ កញ្ញា ឆ្នាំ២០១៤

# មាតិកា


ទំព័រ

បុព្វកថា ........................................ v

សមាសភាព នៃគណៈកម្មការអង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ ២០១៤ ........................................ ix

ផែនទីនៃព្រះរាជាណាចក្រកម្ពុជា ........................................ xi

តួលេខសង្ខេប ........................................ xiii

**ផ្នែក១ : ផែនការសង្ខេប**

ផែនការនៃអង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤ ........................................ I-3

រចនាសម្ព័ន្ធនៃអង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ២០១៤ ........................................ I-9

របាយការណ៍វិភាគស្តីពីលទ្ធផលបឋមនៃ អង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជា ឆ្នាំ២០១៤ ........................................ I-11

**ផ្នែក ២ : ក្រាហ្វិក និង ផែនទី**

ក្រាហ្វិក១: ភាគរយនៃចំនួនសហគ្រាសសរុប បែងចែកតាមរាជធានីខេត្ត ឆ្នាំ ២០១៤ និងភាគរយនៃចំនួនប្រជារាស្ត្រសរុប បែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៣ ........................................ II-3

ក្រាហ្វិក២ :ដង់ស៊ីតេសហគ្រាស បែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ........................................ II-4

ក្រាហ្វិក៣-១: ចំនួនសហគ្រាសក្នុងប្រជារាស្ត្រ១០០០នាក់បែងចែកតាមរាជធានី ខេត្ត ឆ្នាំ២០១៤ ........................................ II-5

ក្រាហ្វិក៣-២: ចំនួនប្រជារាស្ត្រក្នុង ១សហគ្រាសបែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ........................................ II-6

ក្រាហ្វិក៤-១: ចំនួនសហគ្រាសក្នុង១០០០គ្រួសារធម្មតាបែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ........................................ II-7

ក្រាហ្វិក៤-២: ចំនួនគ្រួសារធម្មតាក្នុង ១សហគ្រាសបែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ........................................ II-8

ក្រាហ្វិក៥-១: កំណើនសហគ្រាស បែងចែកតាមរាជធានីខេត្តក្នុងឆ្នាំ ២០១១-២០១៤ . ........................................ II-9

ក្រាហ្វិក៥-២: អត្រាកំណើនសហគ្រាស បែងចែកតាមរាជធានីខេត្តក្នុងឆ្នាំ ២០១១-២០១៤ ........................................ II-10

## ផែនទី


ផែនទី១: ចំនួនសហគ្រាសបែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ..............................II-11
ផែនទី២ :ដង់ស៊ីតេសហគ្រាស បែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ......................II-12
ផែនទី៣-១: ចំនួនសហគ្រាសក្នុងប្រជាពលរដ្ឋ១០០០នាក់បែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ........................................................................................II-3
ផែនទី៣-២: ចំនួនប្រជាពលរដ្ឋក្នុង ១សហគ្រាសបែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ........................................................................................II-14
ផែនទី៤-១: ចំនួនសហគ្រាសក្នុង១០០០គ្រួសារធម្មតាបែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤........................................................................................II-15
ផែនទី៤-២: ចំនួនគ្រួសារធម្មតាក្នុង ១សហគ្រាសបែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ........................................................................................II-16
ផែនទី៥-១: កំណើនសហគ្រាស បែងចែកតាមរាជធានីខេត្តក្នុងឆ្នាំ ២០១១-២០១៤....II-17
ផែនទី៥-២: អត្រាកំណើនសហគ្រាស បែងចែកតាមរាជធានីខេត្តក្នុងឆ្នាំ ២០១១-២០១៤ ........................................................................................II-18


## ផ្នែក៣ : តារាងស្ថិតិ


តារាង១ : ចំនួនសហគ្រាស ភាគរយនៃចំនួនសហគ្រាសសរុប និងលំដាប់ បែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ........................................................III-3
តារាង២ :ដង់ស៊ីតេសហគ្រាស និងលំដាប់ បែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤.......III-4
តារាង៣-១: ចំនួនសហគ្រាសក្នុងប្រជាពលរដ្ឋ១០០០នាក់ បែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤........................................................................................III-5
តារាង៣-២: ចំនួនប្រជាពលរដ្ឋក្នុង ១សហគ្រាសបែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ........................................................................................III-6
តារាង៤-១: ចំនួនសហគ្រាសក្នុង១០០០គ្រួសារធម្មតាបែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤........................................................................................III-7
តារាង៤-២: ចំនួនគ្រួសារធម្មតាក្នុង ១សហគ្រាសបែងចែកតាមរាជធានីខេត្ត ឆ្នាំ២០១៤ ........................................................................................III-8
តារាង៥: កំណើនសហគ្រាស និងអត្រាកំណើនបែងចែកតាមរាជធានីខេត្តក្នុង ឆ្នាំ ២០១១-២០១៤ ........................................................................III-9

## ផ្នែក៤ : ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ១: តារាងសំណួរសហគ្រាស ....................................................................IV-3
ឧបសម្ព័ន្ធ២: តារាងបញ្ជីសហគ្រាស .....................................................................IV-11
ឧបសម្ព័ន្ធ៣: ច្បាប់ស្ថិតិកម្ពុជា..........................................................................IV-13
ឧបសម្ព័ន្ធ៤: ភាពគ្របដណ្តប់នៃអង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤
និងការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជាឆ្នាំ ២០០៩.................IV-27
ឧបសម្ព័ន្ធ៥: ភាពគ្របដណ្តប់នៃជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១១ ..................IV-28

# មុខកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ចំពោះការចេញផ្សាយជាផ្លូវការនូវរបាយការណ៍នៃលទ្ធផលបឋមអង្កេតចន្លោះជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ដែលត្រូវបានអនុវត្តចាប់ពីថ្ងៃទី ១ ដល់ ៣១ ខែ មីនា ឆ្នាំ ២០១៩ ដោយកំណត់យកថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៩ ជាកាលបរិច្ឆេទយោងនៃការអង្កេត ហើយបានគ្រប់ដណ្តប់ពេញដែនដី នៃព្រះរាជាណាចក្រកម្ពុជា។ អង្កេតចន្លោះជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ គឺជាអង្កេតជ្រើសរើសគំរូ និងជាអង្កេតមួយដែលត្រូវបានអនុវត្តរវាងជំរឿន២ គឺស្ថិតនៅចន្លោះជំរឿនសហគ្រាសឆ្នាំ ២០១១ និងជំរឿនសហគ្រាសឆ្នាំ ២០២១។

យោងតាមមូលដ្ឋានគ្រឹះ នៃច្បាប់ស្តីពីស្ថិតិ អង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ ២០១៩ មានគោលបំណងចងក្រងទិន្នន័យស្ថិតិមូលដ្ឋានគ្រឹះស្តីពីអង្គភាពអាជីវកម្ម និងសហគ្រាសគ្រប់ប្រភេទដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ លទ្ធផលបឋមនេះផ្តល់នូវព័ត៌មានស្តីពីស្ថានភាពបច្ចុប្បន្នរបស់អង្គភាពអាជីវកម្ម សហគ្រាសនៅក្នុងប្រទេសកម្ពុជា និងបំរើដល់អ្នកប្រើប្រាស់ផ្សេងៗដូចជាអ្នកធ្វើគោលនយោបាយ មន្ត្រីរាជរដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន អ្នកសិក្សាស្រាវជ្រាវ និងដៃគូរអភិវឌ្ឍន៍ផ្សេងៗទៀត។

លទ្ធផលបឋមនេះ នឹងចូលរួមចំណែកដើម្បីសម្រេចឲ្យបាន នូវគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់រាជរដ្ឋាភិបាលក្នុងការគាំទ្រដល់ការធ្វើផែនការដែលមានភស្តុតាងជាមូលដ្ឋាន ។ ខ្ញុំមានជំនឿថាសាធារណៈជន នឹងទទួលបានផលប្រយោជន៍យ៉ាងច្រើនពីការប្រើប្រាស់លទ្ធផលបឋមនេះឲ្យអស់ពីលទ្ធភាពតាមដែលអាចធ្វើទៅបាន។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានជួយគាំទ្រជាបន្តបន្ទាប់ដល់អង្កេតចន្លោះជំរឿនសហគ្រាសកម្ពុជាឆ្នាំ ២០១៩ ឲ្យទទួលបានជោគជ័យទាំងការងារសម្ភាសន៍ និងការងារកែច្នៃទិន្នន័យ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ និងបណ្តាក្រសួងពាក់ព័ន្ធ

នានាដូចជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហាកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ និងបណ្ដាក្រសួងពាក់ព័ន្ធ ព្រមទាំងស្ថាប័នផ្សេងទៀតដែលបានជួយសម្រួល និងដឹកនាំឲ្យអង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤ ទទួលបានជោគជ័យ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលនៃប្រទេសជប៉ុន និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) ដែលបានផ្តល់ជំនួយទាំងថវិកានិងបច្ចេកទេស និងសូមថ្លែងអំណរគុណដល់លោក **ហ្វូមីហ៊ីកូ នីហ្សឺ** ប្រធានទីប្រឹក្សា JICA នៃគំរោងកែលម្អស្ថិតិផ្លូវការនៅកម្ពុជា លោក **អាគីហ៊ីកូ អ៊ីតូ** លោក **អាគីហ៊ីកូ អ៊ីយ៉ាម៉ាអ៊ូឆិ** លោក **យោឃី សាវ៉ាដា** និងជំនាញការ JICA ផ្សេងៗទៀតនៃគំរោងនេះដែលបានប្រឹងប្រែងអស់ពីកំលាំងកាយ និងកំលាំងចិត្ត ដើម្បីសម្រេចបានជោគជ័យក្នុងការអនុវត្តការងារអង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤ ។

ខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ព្រមទាំងអភិបាលក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ និងប្រធានភូមិទាំងអស់ដែលបានជួយសម្រួលកិច្ចការរដ្ឋបាលក្នុងការអនុវត្តការងារអង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ ២០១៤។

អង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ ២០១៤ គឺជាប្រតិបត្តិការស្ថិតិធំមួយក្នុងចំណោមប្រតិបត្តិការស្ថិតិធំៗផ្សេងទៀត ហើយការសម្រេចបានជោគជ័យនេះ ដោយសារមានការឧបត្ថម្ភ និងកិច្ចសហការយ៉ាងជិតស្និទ្ធពីគ្រប់អង្គភាពទាំងអស់។ ជោគជ័យធំមួយទៀតគឺបានមកពីការចូលរួមរបស់ម្ចាស់អង្គភាពអាជីវកម្ម ម្ចាស់សហគ្រាសធុនតូច មធ្យម និងធំទាំងអស់ដែលបានចំណាយពេលវេលាដ៏មមាញឹក និងមានតំលៃ ដែលបានផ្តល់ព័ត៌មាន និងបំពេញចូលតារាងសំណួរអង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ ២០១៤។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រីសម្ភាសន៍ មន្ត្រីត្រួតពិនិត្យ មន្ត្រីវិទ្យាស្ថានជាតិស្ថិតិនិងក្រសួងផែនការទាំងអស់ ដែលបានខិតខំប្រឹងប្រែងនិងស្មោះត្រង់ក្នុងការងារ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះលោកជំទាវ **ហាង់ លីណា** អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានដឹកនាំប្រតិបត្តិការអង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ ២០១៤ ដោយមានជំនួយការពីលោក **ឃិន សុវលក្ខណ៍** អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ លោក

**សាំង ឡុងឌី** ប្រធាននាយកដ្ឋានបច្ចេកវិទ្យា ទូរគមនាគមន៍ និងព័ត៌មានវិទ្យា លោក **គីម ណេត** អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច លោក **សូ តូនេរ** អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច និងមន្ត្រីវិទ្យាស្ថានជាតិស្ថិតិផ្សេងៗទៀត។

ជាទីបញ្ចប់សូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលបានចូលរួមធ្វើឲ្យការងារអង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ ២០១៤ ទទួលបានជោគជ័យដ៏ត្រចះត្រចង់ ។

ក្រសួងផែនការ
រាជធានីភ្នំពេញ
ខែ កញ្ញា ឆ្នាំ ២០១៤

**ឆាយ ថន**
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងផែនការ

## សមាសភាព នៃគណៈកម្មការបច្ចេកទេស
## សម្រាប់អង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជា ឆ្នាំ ២០១៤

| | |
|---|---|
| ១- ឯកឧត្តម រិន វីរៈ រដ្ឋលេខាធិការ ក្រសួងផែនការ | ប្រធាន |
| ២- ឯកឧត្តម ទុយ ចំរើន អនុរដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ៣- ឯកឧត្តម ហោ ដារិទ្ធ អនុរដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ៤-លោកជំទាវ ហាង់ លីណា អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | សមាជិកអចិន្ត្រៃយ៍ |
| ៥- ឯកឧត្តម គៀក សារិន នាយកខុទ្ទកាល័យ ក្រសួងផែនការ | សមាជិក |
| ៦- លោក ឆាយ សត្យា អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| ៧- លោក មិច កន្នុល ប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| ៨- លោក ចាន់ សុវណ្ណា អនុប្រធាននាយកដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ៩- លោកស្រី ប៉ុល នារីតាន់ អនុប្រធាននាយកដ្ឋាន ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- លោក គី បូរ៉ា អនុប្រធានការិយាល័យ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១១- លោក ហុក ធី ប្រធានការិយាល័យ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១២- លោក គង់ សុភារក្ស ប្រធាននាយកដ្ឋាន ក្រសួងទេសចរណ៍ | សមាជិក |
| ១៣- លោក សូ តូនៃរ អនុប្រធាននាយកដ្ឋាន វិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| ១៤- លោក ឃិន សុវលក្ខណ៍ អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ | លេខាធិការ |
| ១៥- លោក F. Nishi ប្រធានទីប្រឹក្សា គំរោង**JICA** ប្រចាំវិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| ១៦- លោក Akihiko Ito ជំនាញការ **JICA** ប្រចាំវិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| ១៧- លោក Akihito Yamauchi ជំនាញការ **JICA** ប្រចាំវិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| ១៨- លោក Joji Sawada ជំនាញការ **JICA** ប្រចាំវិទ្យាស្ថានជាតិស្ថិតិ | សមាជិក |

# ផែនទីព្រះរាជាណាចក្រកម្ពុជា



# តួលេខសង្ខេប

| | |
|---|---|
| ចំនួនខេត្ត [១] | ២៥ |
| រួមបញ្ចូលរាជធានី | |
| ចំនួនស្រុក ខណ្ឌ ក្រុង[២] | ១៩៧ |
| រួមបញ្ចូល ខណ្ឌចំនួន១២ និងក្រុងចំនួន២៦ | |
| ចំនួនឃុំ សង្កាត់[៣] | ១ ៦៣១ |
| រួមបញ្ចូល សង្កាត់ចំនួន២០៤ | |
| ចំនួនភូមិ[៣], [៤] | ១៤ ១១៩ |
| ចំនួនសហគ្រាសបឋម | ៥១៤ ២៧៨ |
| (លើកលែងអង្គភាពអាជីវកម្ម និងសហគ្រាសតាមចញ្ចើមផ្លូវ) | |
| ចំនួនសហគ្រាសក្នុង ១គីឡូម៉ែត្រការ៉េ | ២,៨ |
| ផ្ទៃដីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១ (គីឡូម៉ែត្រការ៉េ) [៥] | ១៨១ ០៣៥ |
| ចំនួនសហគ្រាសក្នុងមនុស្ស ១០០០នាក់ | ៣៥,០ |
| ប្រជារាស្ត្រឆ្នាំ ២០១៣[៦] | ១៤ ៦៧៦ |
| ៥៩១ | |
| ប្រជារាស្ត្រក្នុងមួយសហគ្រាស | ២៨,៥ |
| ចំនួនសហគ្រាសក្នុង ១០០០គ្រួសារធម្មតា | ១៦២,៦ |
| ចំនួនគ្រួសារធម្មតា [៦] | ៣ ១៦៣ |
| ២២៦ | |
| ចំនួនគ្រួសារធម្មតាក្នុង ១សហគ្រាស | ៦,២ |
| កំណើនសហគ្រាសក្នុងអំឡុងឆ្នាំ ២០១១ដល់ ២០១៤ | ៥០ ៩១៥ |
| អត្រាកំណើនសហគ្រាសក្នុងអំឡុងឆ្នាំ ២០១១ដល់ ២០១៤ | ១១,០ ភាគរយ |

១) ព្រះរាជាណាចក្រកម្ពុជាមានរាជធានី ខេត្ត ចំនួន២៥ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣ នៅខេត្ត កំពង់ចាមត្រូវបានបំបែកចេញជាពីរខេត្ត ខេត្តកំពង់ចាម និងខេត្ត ត្បូងឃ្មុំ។ ម្យ៉ាងវិញទៀត អង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ២០១៤ ត្រូវបានរៀបចំមុនការបំបែកខេត្តនេះ ដោយយោងតាមពេលវេលាកំរិតកំណត់ ដូច្នេះហើយអង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ២០១៤ ត្រូវបានអនុវត្តផ្អែកទៅតាមការបំបែកមុនរបស់ខេត្តពីរនោះ។

២) ចំនួនស្រុក ខណ្ឌ ក្រុង ផ្អែកតាមតំបន់រដ្ឋបាលថ្មី ដែលបានដាក់អោយប្រើប្រាស់ នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៣។ មានខណ្ឌចំនួន៣ ត្រូវបានបង្កើតថ្មីនៅរាជធានី ភ្នំពេញ ហើយខណ្ឌនីមួយៗ នៃខណ្ឌទាំង៣ ត្រូវបានបំបែកទៅជា ២ខណ្ឌ។

៣) ចំនួនឃុំ សង្កាត់ ផ្អែកតាមតំបន់រដ្ឋបាលថ្មីដែលបានដាក់អោយប្រើប្រាស់នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១។

៤) ចំនួនភូមិនៅក្នុងបញ្ជីខាងលើផ្អែកតាមមណ្ឌលអង្កេតនៃជំរឿនសហគ្រាសឆ្នាំ២០១១។ ភូមិដែល មានសហគ្រាសមួយយ៉ាងតិចក៏ត្រូវបានរ៉ាប់បញ្ចូលដែរ ហើយ ប្រសិនបើភូមិដែល គ្មានសហគ្រាស ភូមិនេះមិនត្រូវបានរ៉ាប់បញ្ចូលនៅក្នុងបញ្ជីខាង លើទេ។

៥) ផ្ទៃដីព្រះរាជាណាចក្រកម្ពុជារួមបញ្ចូលផ្ទៃបឹងទន្លេសាប (៣.០០០គីឡូម៉ែត្រការ៉េ)

៦) ប្រជារាស្ត្រ និងចំនួនគ្រួសារធម្មតាត្រូវបានដកស្រង់ចេញពីលទ្ធផលចុងក្រោយនៃ អង្កេតចន្លោះ ជំរឿនប្រជារាស្ត្រទូទៅកម្ពុជាឆ្នាំ២០១៣។

# ផ្នែក១

# ផែនការសង្ខេប

# ផែនការ នៃអង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤

## ១. គោលបំណង នៃអង្កេត

អង្កេតចន្លោះជំរឿនសហគ្រាសកម្ពុជាឆ្នាំ ២០១៤មានគោលបំណងចម្បងដូចជា:

ក)- រក្សា និងបង្កើនចំណេះដឹងនិងជំនាញដែលត្រូវការដើម្បីរៀបចំអនុវត្តការធ្វើជំរឿន និងអង្កេតផ្សេងៗពាក់ព័ន្ធនឹងសេដ្ឋកិច្ច ។

ខ)- រក្សានិងបង្កើនចំណេះដឹង និងជំនាញដែលត្រូវការ ដើម្បីធ្វើបច្ចុប្បន្នកម្ម និងថែទាំងបញ្ជីសហគ្រាសសម្រាប់ធ្វើជាបញ្ជីគំរូនៃការអង្កេតគំរូស្តីពីអាជីវកម្ម។

គ) - ប្រមូលព័ត៌មានស្តីពីសហគ្រាស និងអង្គភាពអាជីវកម្ម

ឃ)-ផ្តល់នូវទិន្នន័យស្ថិតិមូលដ្ឋានស្តីពីសហគ្រាសនិងអាជីវកម្មសម្រាប់រៀបចំផែនការគោលនយោបាយថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ៣ឆ្នាំបន្ទាប់ពីជំរឿនសហគ្រាសឆ្នាំ២០១៨

## ២- បទប្បញ្ញត្តិនៃអង្កេត

អង្កេតចន្លោះជំរឿនសហគ្រាសត្រូវបានអនុវត្តផ្អែកលើមូលដ្ឋានច្បាប់ស្ថិតិ, មាត្រាទី៨ និងទី៩។

## ៣- កាលបរិច្ឆេទយោង និងរយៈពេលធ្វើសម្ភាស

អង្កេតចន្លោះជំរឿនសហគ្រាសកម្ពុជាត្រូវអនុវត្តនៅថ្ងៃទី១ ខែ មីនា ឆ្នាំ២០១៤។

រយៈពេលអង្កេតមានដូចខាងក្រោម:

ក) សម្រាប់សហគ្រាសមានអ្នកចូលរួមការងារ៥០នាក់ឡើងទៅ ការសម្ភាសន៍ត្រូវអនុវត្តក្នុងរយៈពេល១ខែ ចាប់ពីថ្ងៃទី ០១ រហូតដល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៤

ខ) សម្រាប់សហគ្រាសមានអ្នកចូលរួមការងារតិចជាង៥០នាក់ ការបញ្ជាក់លើផែនទីតំបន់អង្កេតត្រូវបានអនុវត្តចាប់ពីថ្ងៃទី ២៣ដល់២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ ហើយការចុះស្រង់បញ្ជីសហគ្រាសគឺចាប់ពី២៤ ដល់ ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ និងការសម្ភាសន៍ចាប់ពីថ្ងៃទី ០១ដល់ ០៥ ខែ មីនា ឆ្នាំ២០១៤។

## ៤- តំបន់អង្កេត

ការអង្កេតចន្លោះជំរឿនសហគ្រាសកម្ពុជាឆ្នាំ២០១៤ គ្របដណ្តប់គ្រប់តំបន់ទាំងអស់នៅក្នុងដែនដីព្រះរាជាណាចក្រកម្ពុជា។

## ៥- វិសាលភាពអង្កេត

ការអង្កេតចន្លោះជំរឿនសហគ្រាស គ្របដណ្តប់គ្រប់សហគ្រាសទាំងអស់ដែលមាន និងដំណើរការអាជីវកម្មក្នុងកាលបរិច្ឆេទកំណត់ ក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមានសហគ្រាសមួយចំនួនត្រូវបានដកចេញដូចខាងក្រោម:

ក-សហគ្រាសស្ថិតក្នុងចំណាត់ថ្នាក់ " ផ្នែក A, កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ" ដែលបានបញ្ជាក់នៅក្នុងចំណាត់ថ្នាក់ស្តង់ដារវិស័យអន្តរជាតិរបស់អង្គការសហប្រជាជាតិ Rev.4

ខ-សហគ្រាសស្ថិតក្នុងចំណាត់ថ្នាក់ " ផ្នែក O, រដ្ឋបាលសាធារណៈ និងសន្តិសុខសង្គមដែលចាំបាច់" ដែល មានបញ្ជាក់នៅ Rev.4 ។

គ-សហគ្រាសនៅក្នុងចំណាត់ថ្នាក់ ផ្នែក T, សកម្មភាពជាម្ចាស់ការ និងសេវាកម្មគ្រួសារសំរាប់ប្រើប្រាស់ ខ្លួនឯង Rev.4 ។

ឃ-សហគ្រាសស្ថិតក្នុងចំណាត់ថ្នាក់"ផ្នែក U, សកម្មភាពអង្គការក្រៅដែនដី" ដែលមានបញ្ជាក់នៅ Rev4។

ង- សហគ្រាសដំណើការអាជីវកម្មនៅតាមចញ្ចើមផ្លូវ។

## ៦. ការជ្រើសរើសគំរូ

សហគ្រាសប្រមាណ១០,០០០ ត្រូវបានជ្រើសរើសដូចខាងក្រោម:

ក) តំបន់សម្ភាសន៍ចំនួន៥៥០ត្រូវបានជ្រើសរើសដោយផ្អែកតាមវិធីសាស្ត្រជ្រើសរើសគំរូចេញពីគ្រប់តំបន់អង្កេតនៅក្នុងខេត្តទាំងអស់។

ខ) គ្រប់សហគ្រាសខ្នាតធំ និងមធ្យម ដែលមានអ្នកចូលរួមការងារពី ៥០នាក់ឡើងទៅត្រូវបានធ្វើសម្ភាសន៍។ អាស្រ័យហេតុនេះ ចំនួនសហគ្រាសមានអ្នកចូលរួមការងារពី៥០នាក់ឡើងទៅមានចំនួន១,៦១៩សហគ្រាស នៅក្នុងជំរឿនសហគ្រាសឆ្នាំ២០១១។

## ៧. អង្គភាពត្រូវធ្វើសម្ភាសន៍

សហគ្រាសដែលត្រូវសម្ភាសន៍សម្រាប់អង្កេតចន្លោះជំរឿនសហគ្រាស ត្រូវបានកំណត់តាមនិយមន័យរបស់អង្គការសហប្រជាជាតិដូចខាងក្រោម:

សហគ្រាសគឺជាអង្គភាពអាជីវកម្មមួយដែលស្ថិតនៅក្រោមការគ្រប់គ្រង ឬកម្មសិទ្ធិមួយដែលស្ថិតនៅក្រោមអង្គភាពស្របច្បាប់មួយ មានសកម្មភាពសេដ្ឋកិច្ចមួយ ឬចម្បងមួយស្ថិតនៅទីតាំងជាក់លាក់មួយដូចជាៈរោងចក្រ រោងជាង ក្រុមហ៊ុន ។ល។

ម្យ៉ាងវិញទៀត សហគ្រាសតាមចញ្ចើមផ្លូវត្រូវបានដកចេញពីអង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ២០១៤នេះ។

## ៨- សំណួរអង្កេត

១- ព័ត៌មានតំបន់: ឈ្មោះ និងកូដ ខេត្ត ស្រុក ខណ្ឌ ក្រុង ឃុំ សង្កាត់ ភូមិ និងមណ្ឌលអង្កេត

២- ព័ត៌មានសហគ្រាស: ឈ្មោះសហគ្រាស អាស័យដ្ឋាន ឈ្មោះអ្នកទំនាក់ទំនងលេខទូរស័ព្ទ

៣.១- ភេទអ្នកតំណាងសហគ្រាស

៣.២- ភេទ និងសញ្ជាតិម្ចាស់សហគ្រាស

៤.១- ការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្ម

៤.២- ឈ្មោះក្រសួង មន្ទីរ ឬស្ថាប័នផ្សេងៗដែលបានផ្តល់អាជ្ញាប័ណ្ណ ឬការអនុញ្ញាត្តិ ដើម្បីបើកដំណើរការអាជីវកម្ម

៥-ភាពជាម្ចាស់កម្មសិទ្ធិ នៃអង្គភាពអាជីវកម្ម សហគ្រាស (លក្ខណៈច្បាប់)

៦- ម៉ោងធ្វើការ

៧-ឆ្នាំចាប់ផ្តើមធ្វើអាជីវកម្ម

៨-ការកាន់កាប់ ប្រភេទនិងផ្ទៃក្រឡា(ជាម៉ែត្រការ៉េ) នៃទីកន្លែងអាជីវកម្ម សហគ្រាស

៩-ចំនួនកម្មករចូលរួមការងារជាក់ស្តែង នៅក្នុងអង្គភាពអាជីវកម្ម សហគ្រាស មួយសប្តាហ៍មុន ថ្ងៃទី១ ខែ មីនា ឆ្នាំ២០១៤

១១-ប្រភេទសកម្មភាពអាជីវកម្មចំបងដែលអង្គភាពអាជីវកម្ម សហគ្រាសបានអនុវត្ត (ចំណាត់ថ្នាក់ឧស្សាហកម្ម)

១១-អង្គភាពទោល ទីស្នាក់ការកណ្តាល ឬ សាខា

**(ប្រធានបទទី១២ -១៤ សម្រាប់ទីស្នាក់ការកណ្តាលតែប៉ុណ្ណោះ)**

១២-ចំនួនសាខា

១៣-ចំនួនអ្នកចូលរួមការងារសរុបដែលធ្វើការជាប្រចាំនៅដំណាច់ខែធ្នូ ឆ្នាំ ២០១០ ។

១៤-ប្រភេទសកម្មភាពអាជីវកម្មចំបង និងបន្ទាប់បន្សំចំបងរបស់សហគ្រាស ។

**(ប្រធានបទទី១៥ -២១ សម្រាប់ទីស្នាក់ការកណ្តាល និងអង្គភាពទោលតែប៉ុណ្ណោះ)**

១៥-តើសហគ្រាសនេះមានឯកសារស្តីពីការចូលរួមទុនតារាងតុល្យការ និង របាយការណ៍ចំណូលចំណាយឬទេ?

**(សំណួរទី១៦ សំដៅដល់សហគ្រាសទាំងអស់ជាអង្គភាពទោល ឬទីស្នាក់ការកណ្តាលដែល សហគ្រាស ឆ្លើយសំណួរទី ១៥ ថា " ទេ")**

១៦-១-ចំណូលពីការលក់សរុបក្នុងមួយខែឬ មួយថ្ងៃជាប្រាក់រៀល ឬដុល្លារអាមេរិក

១៦-២-ចំណាយសរុបក្នុងមួយខែឬ មួយថ្ងៃជាប្រាក់រៀល ឬដុល្លារអាមេរិក

១៦-២-១-ប្រាក់ខែឬប្រាក់ឈ្នួលសរុបក្នុងមួយខែឬមួយថ្ងៃជាប្រាក់រៀល ឬដុល្លារអាមេរិក

១៦-២-២-ចំណាយលើអគ្គីសនីសរុប (សម្រាប់ជាវតែប៉ុណ្ណោះ)

១៦-៣-ចំនួនថ្ងៃធ្វើការក្នុងខែកុម្ភៈ ឆ្នាំ ២០១៤

**(សំណួរទី១៧ដល់ ២១ សំដៅដល់សហគ្រាសទាំងអស់ជាអង្គភាពទោល ឬទីស្នាក់ការកណ្តាល ដែល សហគ្រាស ឆ្លើយសំណួរទី ១៥ ថា " មាន)**

១៧- ចំនួនទ្រព្យសកម្មសរុបនៅចុងខែធ្នូ ឆ្នាំ ២០១៣

១៨- ចំនួនមូលនិធិម្ចាស់ទ្រព្យសរុបដែលមាននៅដំណាច់ខែធ្នូ ឆ្នាំ ២០១៣

១៩- ចំនួនបំណុលរយៈពេលវែងសរុបដែលមាននៅចុងខែធ្នូ ឆ្នាំ២០១៣

២០-បំណុលរយៈពេលខ្លីសរុបដែលមាននៅចុងខែធ្នូ ឆ្នាំ២០១៣

២១- របាយការណ៍ចំណូល និងចំណាយក្នុងអំឡុងឆ្នាំ២០១៣ តាម "មូលដ្ឋានប្រពន្ធ័គណនេយ្យ" ដែលកត់ត្រាពីចំណូលនិងចំណាយផ្សេងៗក្នុងអំឡុងឆ្នាំ ២០១៣ ។

## ៩- រចនាសម្ព័ន្ធ

ជាទូទៅការអង្កេតចន្លោះជំរឿនត្រូវបានអនុវត្តដូចខាងក្រោមៈ

**១-បណ្តាញរដ្ឋបាលៈ**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ (អគ្គនាយកនៃជំរឿនសហគ្រាស) ⇒ប្រធានមន្ទីរផែនការរាជធានី ខេត្ត ⇒អភិបាលស្រុក ខណ្ឌ ក្រុង ⇒មេឃុំ នៅសង្កាត់ ⇒ ប្រធានភូមិ។

**២-បណ្តាជញអង្កេតៈ**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ (អគ្គនាយកនៃជំរឿនសហគ្រាស) ⇒ មន្ត្រីសម្របសម្រួលអង្កេតជាន់ខ្ពស⇒ មន្ត្រីប្រចាំតំបន់ ⇒ ជំនួយការមន្ត្រីប្រចាំតំបន់ ⇒មន្ត្រីត្រួតពិនិត្យ ⇒មន្ត្រីសម្ភាសន៍ ។

មន្ត្រីសម្របសម្រួលអង្កេតជាន់ខ្ពសគ្រប់គ្រងដំណើរការអង្កេតទាំងមូល ហើយមន្ត្រីប្រចាំតំបន់ម្នាក់ និងជំនួយការមន្ត្រីប្រចាំតំបន់ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវខេត្តមួយ និងគ្រប់គ្រងដំណើការអង្កេតទាំងមូលនៅក្នុងខេត្តដែលទទួលខុសត្រូវ។

**៣-មន្ត្រីសម្របសម្រួលរាជធានី ខេត្ត**

មន្ត្រីសម្របសម្រួលរាជធានី ខេត្តម្នាក់ ត្រូវបានជ្រើសរើសចេញពីក្រសួង ឬមន្ទីរពាក់ព័ន្ធពីរាជធានី ខេត្តនីមួយៗ ដើម្បីឲ្យជួយបញ្ចុះបញ្ចូលសហគ្រាសបដិសេធន៍ក្នុងករណីចាំបាច់។

សូមពិនិត្យមើលតារាងរចនាសម្ព័ន្ធនៃអង្កេតចន្លោះជំរឿនសហគ្រាស

## ១០- វិធីសាស្ត្រនៃការសម្ភាសន៍

អង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ ២០១៤ត្រូវអនុវត្តតាមវិធីសាស្ត្រ២យ៉ាងៈ

"ការសម្ភាសន៍សហគ្រាស នៅភូមិគំរូត្រូវសម្ភាសន៍ដោយមន្ត្រីសម្ភាសន៍" និង"ការសម្ភាសន៍សហគ្រាសដែលមានអ្នកចូលរួមការងារពី៥០នាក់ឡើងទៅត្រូវសម្ភាសន៍ដោយមន្ត្រីប្រចាំតំបន់ និងជំនួយការមន្ត្រីប្រចាំតំបន់"

ក)-ការសម្ភាសន៍សហគ្រាសនៅភូមិគំរូត្រូវសម្ភាសន៍ដោយមន្ត្រីសម្ភាសន៍

មន្ត្រីសម្ភាសន៍ម្នាក់ធ្វើដំណើរទៅកាន់ភូមិ ឬមណ្ឌលអង្កេតទទួលខុសត្រូវ ហើយធ្វើ

ការចុះស្រង់បញ្ជីសហគ្រាសនៅក្នុងមណ្ឌលអង្កេត ជ្រើសរើសសហគ្រាសចំនួន៣០ ប្រសិនបើមានសហគ្រាសច្រើនជាង៣០នៅក្នុងតារាងបញ្ជីសហគ្រាស បន្ទាប់មកសម្ភាសម្ចាស់ឬអ្នកគ្រប់គ្រងសហគ្រាស ឬអ្នកណាម្នាក់ដែលត្រូវបានគេប្រគល់សិទ្ធិអោយតំណាងសហគ្រាស ហើយបំពេញព័ត៌មានចូលក្នុង តារាងសំណួរសហគ្រាស ។

ខ)-ការសម្ភាសន៍សហគ្រាសដែលមានអ្នកចូលរួមការងារពី៥០នាក់ឡើងទៅត្រូវ
សម្ភាសន៍ ដោយមន្ត្រីប្រចាំតំបន់ និងជំនួយការមន្ត្រីប្រចាំតំបន់

មន្ត្រីប្រចាំតំបន់ និងជំនួយការមន្ត្រីប្រចាំតំបន់ត្រូវធ្វើដំណើរទៅកាន់សហគ្រាសនីមួយដែលមាននៅក្នុងតារាងបញ្ជីសហគ្រាសបឋម ដែលបានរៀបចំចេញពីជំរឿនសហគ្រាសឆ្នាំ២០១១ ហើយនិងព័ត៌មានផ្សេងទៀតដែលទទួលបានពីមន្ត្រីខេត្ត បន្ទាប់មកសម្ភាសម្ចាស់ឬអ្នកគ្រប់គ្រងសហគ្រាស ឬអ្នកណាម្នាក់ដែលត្រូវបានគេប្រគល់សិទ្ធិ អោយតំណាងសហគ្រាសហើយបំពេញព័ត៌មានចូលក្នុងតារាងសំណួរសហគ្រាស។

## ១១-ការគូសផែនទី

ការងារគូសផែនទីត្រូវបានអនុវត្តសម្រាប់តែភូមិឬមណ្ឌលអង្កេតគំរូ ដែលមានព្រំប្រទល់ប្រែប្រួលក្រោយខែមីនាឆ្នាំ២០១១ និងភូមិឬមណ្ឌលអង្កេតគំរូដែល មានចំនួនចាប់ពី១៣០សហគ្រាសឡើងទៅ នៅក្នុងជំរឿនសហគ្រាសឆ្នាំ ២០១១ និងគូសឡើងវិញសម្រាប់តំបន់អភិវឌ្ឍន៍ថ្មី ដូចជា តំបន់សេដ្ឋកិច្ចពិសេស។

ផែនទីព្រំប្រទល់មណ្ឌលអង្កេតគំរូ ត្រូវបានគូសផ្អែកតាមផែនីទភូមិឬមណ្ឌលអង្កេតជំរឿនសហគ្រាសឆ្នាំ ២០១១ គូសដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ។

## ១២-ការសាកល្បងតារាងសំណួរអង្កេត

ក-ការសាកល្បងតារាងសំណួរមានបំណង ធ្វើតេស្តលើតារាងសំណួរ វិធីសាស្រ្តសម្ភាសន៍ឯកសារណែនាំរបស់មន្ត្រីសម្ភាសន៍ជាដើម ដើម្បីធ្វើឲ្យផែនការនៃការងារអង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ ២០១៤បានកាន់តែប្រសើរ។

ខ-ការសាកល្បងតារាងសំណួរបានអនុវត្តចំនួន១៥ភូមិនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ មានរយៈពេល ១១ ថ្ងៃ។

## ១៣- ការប្រកាសផ្សព្វផ្សាយនៃលទ្ធផលអង្កេត

ក)-លទ្ធផលបឋមនៃអង្កេតចន្លោះជំរឿនសហគ្រាសកម្ពុជាឆ្នាំ ២០១៤ នឹងត្រូវផ្សព្វផ្សាយនៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤

ខ)- លទ្ធផលចុងក្រោយនៃអង្កេតចន្លោះជំរឿនសហគ្រាសកម្ពុជាឆ្នាំ ២០១៤ នឹងត្រូវផ្សព្វផ្សាយនៅខែ កុម្ភៈ ឆ្នាំ ២០១៥។

**១៤- ការផ្សព្វផ្សាយ**

ការបោះពុម្ពផ្សាយជាសៀវភៅនឹងធ្វើជាពីរភាសា ទាំងភាសាខ្មែរ និង អង់គ្លេស ហើយនិងផ្សព្វផ្សាយតាមប្រពន្ធ័អេឡិចត្រូនិចផងដែរ។

# រចនាសម្ព័ន្ធនៃអង្កេតចន្លោះជំរឿន
# សហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤ (CIES)



## របាយការណ៍ការវិភាគ
## លទ្ធផលបឋមនៃជំរឿនអង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤

### ១- ចំនួនសហគ្រាសសរុបនៅកម្ពុជា លើកលែងអាជីវកម្មតាមចិញ្ចើមផ្លូវ មានចំនួន **៥១៤,២៧៨ សហគ្រាស** (យោងតារាង ១, ក្រាហ្វ ១ និងផែនទី ១)

លទ្ធផលបឋមនៃអង្កេតចន្លោះជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤ (CIES 2014) ផ្តល់ព័ត៌មានស្តីពីស្ថានភាពសហគ្រាសបច្ចុប្បន្ននៅកម្ពុជាក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចក្រោយពីការបោះឆ្នោតសកលនៅ ខែកក្កដា ឆ្នាំ ២០១៣។ តួលេខសង្ខេបគឺមានគោលបំណងផ្សព្វផ្សាយចំនួនសហគ្រាសឲ្យបានលឿន។ ដូច្នេះលទ្ធផលបឋមប្រហែលជាខុសគ្នាបន្តិចបន្តួចពីលទ្ធផលចុងក្រោយដែលនឹងប្រកាសផ្សព្វផ្សាយនៅខែកុម្ភៈឆ្នាំ ២០១៥។

ព្រះរាជាណាចក្រកម្ពុជាគិតត្រឹមថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៤ មាន ៥១៤.២៧៨ សហគ្រាស យោងតាមលទ្ធផលបឋម នៃលទ្ធផលអង្កេតចន្លោះជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៤ ដែលបានអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិ (វ ជ ស) ក្រសួងផែនការ កម្ពុជា។ អង្កេតចន្លោះជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៤ គ្របដណ្តប់២៤រាជធានី ខេត្តនៅក្នុងប្រទេស និងធ្វើការសម្ភាសគ្រឹះស្ថានសហគ្រាស អង្គភាពអាជីវកម្មប្រហែល ១២,០០០ សហគ្រាស ។ ម្យ៉ាងទៀតសហគ្រាសដែលស្ថិតនៅក្នុងចំណាត់ថ្នាក់វិស័យសេដ្ឋកិច្ចស្តង់ដារអន្តរ (ISIC) Rev 4 ត្រូវបានដកចេញយោងតាមការណែនាំជាអន្តរជាតិក្នុងការធ្វើជំរឿន និងអង្កេតសេដ្ឋកិច្ច, (ជំពូក ក ) ផ្នែកកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ, (ជំពូក ណ) ផ្នែករដ្ឋបាលសាធារណៈ និងការពារជាតិ, (ជំពូក.ន) សកម្មភាពរបស់គ្រួសារធ្វើការជានិយោជិក និងសកម្មភាពផលិតកម្មទំនិញ និងផ្គត់ផ្គង់សេវាកម្មរបស់គ្រួសារសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (ជំពូក. ប) សកម្មភាពរបស់អង្គការ និងស្ថាប័នអន្តរជាតិ។ សហគ្រាសចល័តក៏ត្រូវបានដកចេញផងដែរយោងតាមការអនុវត្តជាលក្ខណៈអន្តរជាតិ។ (យោងតាមឧបសម្ព័ន្ធ ៤ និង តាមឧបសម្ព័ន្ធ ៥)

នៅកម្ពុជាមានសហគ្រាសសរុបទូទាំងប្រទេស ៥១៤,២៧៨ សហគ្រាស ហើយចំនួនសហគ្រាសក្នុង ១០០០ នាក់ គឺ ៣៥.០ សហគ្រាស។ នៅពេលធ្វើការប្រៀបធៀបជាមួយនឹងប្រទេសផ្សេងៗ ប្រទេសជប៉ុនមានសហគ្រាស ៥,៨ លាន សហគ្រាស និង ៤៥,៤សហគ្រាស ក្នុងមនុស្ស ១០០០ នាក់, ប្រទេសវៀតណាមមានសហគ្រាស សរុប ៥.២ លាន សហគ្រាស និង ៥៨,២ ចំណែកឯប្រទេសឡាវមានសហគ្រាសចំនួន ២០៩ ពាន់សហគ្រាស និង៣៧,៤ ក្នុងមនុស្ស ១០០០ នាក់។ ក្នុងចំណោមប្រទេសទាំង ៤ នេះប្រទេសកម្ពុជាមានសហគ្រាសទំនាក់ទំនងតិចជាងធៀបនឹងទំហំប្រជាពលរដ្ឋទោះបីជាមានកំណើនកើនឡើង ។[9]

*[9] ប្រភពទិន្នន័យប្រជាពរដ្ឋប៉ាន់ស្មាន ឆ្នាំ២០១៤ និងជំរឿនសេដ្ឋកិច្ចនៅប្រទេសជប៉ុនឆ្នាំ ២០១២ ការព្យាករណ៍ប្រជាពរដ្ឋ និងជំរឿនសេដ្ឋកិច្ចនៅប្រទេសវៀតណាមឆ្នាំ២០១២ និងជំរឿនប្រជាពរដ្ឋឆ្នាំ*

*២០០៥ និងដំណើរសេដ្ឋកិច្ចឆ្នាំ ២០០៦នៅប្រទេសឡាវ។ ការកំណត់និយមន័យមានភាពខុសគ្នាបន្តិចបន្តួច នៅក្នុងចំណោមប្រទេសទាំងបួន។*

ខេត្តដែលមានចំនួនសហគ្រាសច្រើនជាងគេបំផុត គឺរាជធានីភ្នំពេញ មានសហគ្រាសរហូតដល់ទៅ ៩៨,៦៤៦ សហគ្រាស ឬស្មើនឹង ១៩,២% ធៀបនឹងចំនួនសហគ្រាសសរុបនៅកម្ពុជា ខេត្តដែលមានសហគ្រាសច្រើនបន្ទាប់មក គឺខេត្តកំពង់ចាម (៥៤,២២៩ ឬស្មើនឹង ១០,៥%) ខេត្តកណ្តាលមានសហគ្រាស (៣៨,៦៦៤ ឬស្មើនឹង៧,៥%) ខេត្តសៀមរាបមានសហគ្រាសចំនួន (៣៧,៦១៧ ឬ៧,៣%) និងខេត្តតាកែវមាន សហគ្រាស ៣២,៧៧៨ ឬស្មើនឹង ៦,៤%)។ ខេត្តទាំង ៥នេះស្ថិតនៅក្នុងតំបន់វាលទំនាប ឬ នៅតាមបឹងទន្លេសាប, សហគ្រាសជាង ៥០% ធៀបនឹងសហគ្រាសសរុបទូទាំងប្រទេសកម្ពុជា។

រាជធានីភ្នំពេញមានទំហំចំនួនសហគ្រាសកាន់តែធំសម្បើម។ នេះយើងអាចនិយាយបានថាដោយសារការបំបែកខេត្តកណ្តាលចំនួន ២០ ឃុំដាក់បញ្ចូលមករាជធានីភ្នំពេញកាលពីឆ្នាំ២០១០ ម៉្យាងទៀតក៏ដោយការអភិវឌ្ឍន៍ និងភាពរីកចម្រើនរបស់រាជធានីភ្នំពេញនៃប្រទេសកម្ពុជា ដូចដែលយើងសង្កេតឃើញថា សហគ្រាសផ្នែកលក់ដុំ និងលក់រាយ សណ្ឋាគារ ផ្ទះសំណាក់ អាហារដ្ឋាន។ល។ មានការកើនឡើងច្រើនគួរឲ្យកត់សំគាល់ ក៏ដូចជាការសាងសង់អគារខ្ពស់ៗជាដើម។ រោងចក្រកាត់ដេរខ្នាតធំជាច្រើនមានតម្រូវការ និងបានជួលកម្លាំងពលកម្មជាច្រើននៅក្នុងទីផ្សារពលកម្ម។

ខេត្តកំពង់ចាម យើងសង្កេតឃើញថាមានសហគ្រាសលក់ដុំ និងលក់រាយ ឡតដូ និង ម៉ាស៊ីនកិនស្រូវជាច្រើនបន្ថែមពីលើវិស័យសេដ្ឋកិច្ចចម្បងជាច្រើនដូចជា កៅស៊ូ ការផលិតម្សៅដំឡូងមី ការចិញ្ចឹមសត្វពាហនៈ រោងចក្រផលិតស្បែកជើង អាជីវកម្មអារឈើ និងរោងចក្រផលិតសម្លៀកបំពាក់ជាដើម។ បន្ថែមពីនេះទៀត បង្ហាញឲ្យឃើញថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានដើរតួនាទីសំខាន់នៅក្នុងសកម្មភាពសេដ្ឋកិច្ចទាំងនេះ។ វិថីក្នុងទីក្រុងមួយចំនួនទើបតែចាក់ក្រាសកៅស៊ូរួច ក្នុងរយៈពេលពី ឬបីឆ្នាំថ្មីៗនេះ ហើយការផ្គត់ផ្គង់ថាមពលអគ្គីសនីមកពីប្រទេសវៀតណាមត្រូវបានពង្រីកវិសាលភាពគ្របដណ្តប់ទូទាំងខេត្តកំពង់ចាម។ ភាពរីកចម្រើនទាំងនេះនៅមានផលប៉ះពាល់ដល់ការពង្រីកវិស័យអាជីវកម្ម និងពាណិជ្ជកម្មនៅឡើយ ដូចជាការលំបាកធ្វើដំណើររបស់កសិករ មកពីទីជនបទមកកាន់ទីក្រុងដើម្បីលក់ផលិតផលកសិកម្ម ឬផលិតផលសិប្បកម្មផ្ទាល់ខ្លួនរបស់ពួក គាត់ ជាពិសេសនៅក្នុងរដូវរាំងស្ងួត។

ខេត្តកណ្តាល កំពង់ផែភ្នំពេញថ្មីមួយត្រូវបានសាងសង់ឡើងហើយបណ្តាលឲ្យចំនួនសហគ្រាសនៅក្នុងខេត្តនេះមានការកើនឡើងតិចតួចផងដែរ ទោះបីជាខេត្តនេះបានកាត់ឃុំចំនួន ២០ ឃុំ បញ្ចូលមករាជធានីភ្នំពេញក៏ដោយ។ សហគ្រាសផ្នែកពាណិជ្ជកម្មលក់ដុំ និងលក់រាយមានការកើនឡើងច្រើន។ បន្ថែមពីនេះទៀតស្ពានព្រែកតាមាក់ឆ្លងកាត់ទន្លេមេគង្គ និងស្ពានព្រែកក្តាមឆ្លងកាត់ទន្លេសាបហាក់ដូចជានៅមានផលប៉ះពាល់ទៅចំនួនសហគ្រាសកើនឡើងនៅឡើយ។ ផ្ទុយទៅវិញ ការធ្វើអាជីវកម្មរែបានថយចុះនៅក្នុងខេត្តនេះ។

ទទឹមនេះដែរ ខេត្តដែលមានសហគ្រាសតិចបំផុត គឺខេត្តកែប មានសហគ្រាសចំនួន ១,៦០៧ សហគ្រាស ឬស្មើនឹង ០,៣% ធៀបនឹងសហគ្រាសសរុប នេះប្រហែលជាឆ្លុះបញ្ចាំងឲ្យឃើញការពិតថាខេត្តកែបគឺជាខេត្តដែលមានផ្ទៃដីតូចបំផុតក្នុងចំណោមរាជធានី ខេត្តទាំងអស់, បន្ទាប់មក គឺខេត្តមណ្ឌលគីរី មានសហគ្រាសចំនួន ២,៥៩៤ សហគ្រាស ស្មើនឹង ០,៥%, ខេត្តប៉ៃលិនមានសហគ្រាសចំនួន ២,៩៤៥ ឬ ០,៦%, ខេត្តស្ទឹងត្រែងមានសហគ្រាស ៤,៦០៨ សហគ្រាស ឬស្មើនឹង ០,៩% និងខេត្តឧត្តរមានជ័យមានសហគ្រាស ៥,០៤២ សហគ្រាស ឬស្មើនឹង ១,០%។ ខេត្តទាំង ៥នេះស្ថិតភាគខាងជើង និងភាគខាងកើតនៃប្រទេសកម្ពុជាលើកលែងខេត្តកែប។

## ២- ដង់ស៊ីតេសហគ្រាសក្នុង ១ គីឡូម៉ែត្រការ៉េ នៅកម្ពុជា គឺ ២,៨ សហគ្រាស

(យោងតារាង ២ ក្រាហ្វ ២ និងផែនទី ២)

ខេត្តដែលមានដង់ស៊ីតេសហគ្រាសខ្ពស់ជាងគេបំផុតគឺរាជធានីភ្នំពេញ មានសហគ្រាសចំនួន ១៦៣.៦ សហគ្រាសក្នុង ១គីឡូម៉ែត្រការ៉េ បន្ទាប់មកខេត្តកណ្ដាល (១១.៩) ខេត្តតាកែវ (៩.២) ខេត្តព្រៃវែង (៦.០) និងខេត្តព្រះសីហនុ (៥.៦)។ ខេត្តទាំង ៥នេះ គឺស្ថិតនៅប៉ែកភាគខាងត្បូងនៃប្រទេស ហើយស្ថិតនៅតំបន់វាលទំនាប។

ខេត្តព្រៃវែង គឺជាខេត្តមួយដែលមានម៉ាស៊ីនកិនស្រូវច្រើន និងមានរោងម៉ាស៊ីនកិនស្រូវខ្នាតធំចំនួន ៩ ដែលភាគច្រើនកិនស្រូវសម្រាប់នាំចេញ។ ផ្លូវជាតិលេខ ៨ ទើបតែបានចាក់ក្រាលកៅស៊ូរួចរាល់ រយៈពេលពី ឬបីឆ្នាំ ចំណែកឯស្ពានព្រែកតាម៉ាក់ឆ្លងកាត់ទន្លេមេគង្គក៏ទើបត្រូវបានសាងសង់រួចថ្មីៗ។ ភាពរីកចម្រើនផ្នែករចនាសម្ព័ន្ធទាំងនេះនៅតែបង្ករឲ្យមានផលប៉ះពាល់ដល់ការកើនឡើងគ្រោះថ្នាក់ចរាចរណ៍នៅឡើយ។

ខេត្តព្រះសីហនុ មានតំបន់សេដ្ឋកិច្ចពិសេស កំពង់ផែស្វ័យត និងរមណីដ្ឋាន គឺជាវិស័យឧស្សហាកម្មសំខាន់។ ខេត្តនេះក៏មានរោងចក្រផលិតសម្លៀកបំពាក់ រោងចក្រផលិតស្បែកជើង រោងចក្រផលិតស្រាបៀរ និងឧស្សាហាកម្មប្រេងឥន្ទនៈ។ បន្ថែមពីនេះទៀតរដ្ឋាករទឹកស្វ័យត និងការផ្គត់ផ្គង់ថាមពលអគ្គីសនី។

នៅក្នុងខណៈពេលនេះដែរ ខេត្តដែលមានដង់ស៊ីតេសហគ្រាសទាបជាងគេបំផុត គឺខេត្តមណ្ឌលគីរីមានដង់ស៊ីតេ ០.២ ក្នុង១ គីឡូម៉ែត្រការ៉េ ស្របគ្នាទៅនឹងស្ថានភាពជាក់ស្តែងខេត្តនេះមានដង់ស៊ីតេ ប្រជារាស្ត្រទាបជាងគេបំផុត។ ខេត្តមណ្ឌលគីរីមានដង់ស៊ីតេទាបបំផុតបន្ទាប់ពីខេត្តស្ទឹងត្រែង (០.៤) ខេត្តព្រះវិហារ (០.៤) ខេត្តកោះកុង (០.៥) រីឯខេត្តរតនគីរីមានដង់ស៊ីតេ(០.៦)។ ខេត្តទាំង ៥នេះគឺស្ថិតនៅតាមខ្សែបន្ទាត់ព្រំដែនប្រទេសជ្រុងៗ។

ខេត្តមណ្ឌលគីរី វិស័យឧស្សាហាកម្មចំបង គឺផលិត និងលក់ចែកចាយផលិតផលគ្រឿងសង្ហារឹមធ្វើអំពីឈើ, សណ្ឋាគារ ផ្ទះសំណាក់ ភោជនីដ្ឋាន អាជីវកម្មលក់សម្ភារៈគ្រឿងសំណង់ យានដ្ឋានជួសជុលរថយន្ត និងលក់គ្រឿងបន្លាស់រថយន្ត។ ការចាក់ក្រាលថ្នល់កៅស៊ូនៅមានផល

ប៉ះពាល់ដល់ឱកាសបង្កើនកិច្ចការការងារជំនួញចំពោះប្រជាជននៅតំបន់នោះនៅឡើយ។ ផ្ទុយទៅវិញការធ្វើអាជីវកម្មរ៉ែមាស និងរ៉ែដែកត្រូវបានបិទជាបណ្តោះអាសន្ន។

## ៣.១. ចំនួនសហគ្រាសក្នុងមនុស្ស ១០០០ នាក់ នៅកម្ពុជា គឺ ៣៥.០ សហគ្រាស

(យោងតារាង៣.១, ក្រាហ្វ ៣.១, និងផែនទី ៣.១)

ខេត្តដែលធំជាងគេបំផុតក្នុងលក្ខខណ្ឌចំនួនសហគ្រាសក្នុងមនុស្ស ១០០០ នាក់ គឺ រាជធានីភ្នំពេញ ដែលមានសហគ្រាស ៥៨.៤ សហគ្រាស បន្ទាប់មកខេត្តប៉ៃលិន(៤៩.៨) ខេត្តកោះកុង (៤៩.៦) ខេត្តកំពង់ឆ្នាំង (៤៣.៦) និងខេត្តព្រះសីហនុ (៤៣.១)។ ខេត្តទាំង ៥នេះគឺស្ថិតនៅប៉ែកខាងលិច ឬផ្ទៃកកណ្តាលនៃប្រទេស និងស្ថិតនៅតំបន់វាលទំនាប ឬនៅតំបន់ជាប់សមុទ្រដែលជាតំបន់ដែលមានការប្រកួតប្រជែងច្រើនសម្រាប់ការងារជំនួញ។

ខេត្តកោះកុង មានសហគ្រាសខ្នាតធំចំនួន៩ ក្នុងនោះសហគ្រាសខ្នាតធំ៨ ស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ តំបន់សេដ្ឋកិច្ចពិសេសមាន រោងចក្រតំឡើរថយន្ត រោងចក្រផលិតគ្រឿងបន្លាស់រថយន្ត រោងចក្រផលិតឧបករណ៍កីឡា រោងចក្រស្ករស និងរោងចក្រកាត់ដេរ។ លើសពីនេះទៀតមាន កាស៊ីណូ រមនីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងមានសហគ្រាសសំខាន់ៗផ្សេងទៀតជាច្រើន។

ខេត្តកំពង់ឆ្នាំង វិស័យសេដ្ឋកិច្ចចម្បង គឺផលិតកម្មកាត់ដេរ។ រោងចក្រកាត់ដេរជាច្រើនបានផ្តល់នូវប្រាក់បៀវត្សសមរម្យចំពោះអ្នកដែលបានចូលរួមការងារ ហើយបានលើកកំពស់លក្ខខណ្ឌរស់នៅរបស់ពួកគាត់កាន់តែប្រសើឡើង។ វិស័យនេះបានធ្វើឲ្យអ្នកចូលរួមការងារផ្លាស់ប្តូរការងារពីវិស័យចម្បងទី១ ទៅវិស័យចម្បងទី ២ ឬវិស័យទី៣បន្តិចម្តងៗ។ ដូចគ្នានេះដែរមិនត្រឹមតែសហគ្រាសខ្នាតធំប៉ុណ្ណោះទេ ប៉ុន្តែសហគ្រាសខ្នាតតូចក៏បានដើរតួនាទីសំខាន់ផងដែរក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា។

នៅក្នុងខណៈពេលនេះដែរ ខេត្តដែលមានសហគ្រាសទាបបំផុតក្នុងមនុស្ស ១០០០ នាក់ គឺខេត្តឧត្តរមានជ័យ មាន ២១.៨ សហគ្រាស ទាបបន្ទាប់ពីខេត្តស្វាយរៀង (២៥.១) ខេត្តព្រៃវែង (២៥.៥) ខេត្តព្រះវិហារ (២៦.១) និងខេត្តកំពត (២៦.៩)។ មានន័យថាអាចមានទីកន្លែងដែលអាចបង្កើតសហគ្រាសបានច្រើនថែមទៀតនៅខេត្តទាំង ៥នេះ បើប្រៀបធៀបទៅនឹងចំនួនប្រជាជននៅក្នុងខេត្តទាំង ៥នេះ។

## ៣.២. ប្រជារាស្ត្រក្នុង ១សហគ្រាសនៅកម្ពុជា គឺ ២៨,៥ នាក់

(យោងតារាង ៣.២, ក្រាហ្វ៣,២, និងផែនទី ៣.២)

ខេត្តដែលមានមនុស្សច្រើនជាងគេបំផុតក្នុង១សហគ្រាស គឺខេត្តឧត្តរមានជ័យ មាន ៤៥,៩ នាក់ក្នុង ១សហគ្រាស បន្ទាប់មកគឺខេត្តស្វាយរៀង (៣៨,៨) ខេត្តព្រៃវែង (៣៩,២) ខេត្តព្រះវិហារ (៣៨,៤) និងខេត្តកំពត (៣៧,២)។ នៅក្នុងខេត្តទាំង ៥ នេះ មានចំនួនប្រជាពលរដ្ឋច្រើនក្នុង ១ សហគ្រាស ហើយខេត្តនេះនៅមានកន្លែងអាចបង្កើតសហគ្រាស ឬអាជីវកម្មបានបន្ថែមទៀត។

នៅក្នុងខណៈពេលនេះដែរ ខេត្តដែលមានប្រជាពលរដ្ឋទាបបំផុតគិតក្នុង ១សហគ្រាសដូចគ្នា គឺរាជធានីភ្នំពេញ មាន ១៧,១ នាក់ បន្ទាប់ខេត្តប៉ៃលិន (២២.៣) ខេត្តកោះកុង (២២,៤) ខេត្តកំពង់ឆ្នាំង (២២,៩) និងខេត្តព្រះសីហនុ (២៣,២)

## ៤.១ ចំនួនសហគ្រាសក្នុង ១០០០ គ្រួសារ នៅកម្ពុជា គឺ ១៦២,៦សហគ្រាស

(យោងតារាង ៤.១, ក្រាហ្វ ៤.១ និងផែនទី ៤.១)

ខេត្តដែលមានចំនួនសហគ្រាសច្រើនជាងគេបំផុតគិតក្នុង ១០០០ គ្រួសារ គឺរាជធានីភ្នំពេញ មាន២៧៩,៧ សហគ្រាស បន្ទាប់មកខេត្តកោះកុង (២១២,៥) ខេត្តព្រះសីហនុ (២០៧,៧) ខេត្តកំពង់ឆ្នាំង (២០៥,០) និងខេត្តប៉ៃលិន (២០៣,៣)។ ខេត្តទាំង ៥ នេះគឺជាខេត្តដែលមានភាពប្រកួតប្រជែងគ្នាសម្រាប់ការងារជំនួញ។

នៅក្នុងខណៈពេលនេះដែរ ខេត្តដែលមានសហគ្រាសទាបបំផុតគិតក្នុង ១០០០ គ្រួសារដូចគ្នាគឺខេត្តឧត្តរមានជ័យ មានសហគ្រាស ១០០,៣ សហគ្រាស បន្ទាប់មកខេត្តស្វាយរៀង (១១០,៩) ខេត្តព្រៃវែង (១១៥,៣) ខេត្តកំពត (១២០,៩)និងខេត្តព្រះវិហារ (១២៧,២)។ ខេត្តទាំង ៥នេះមានស្ថានភាពសហគ្រាសទាបបង្គួរដូចដែលបានប្រៀបធៀបទៅនឹងស្ថានភាពដង់ស៊ីតេសហគ្រាសនៅក្នុងខេត្តទាំង ៥នេះ លើកលែងតែខេត្តព្រះវិហារ។ មានន័យថានៅមានទីកន្លែងអាចបង្កើតសហគ្រាសបន្ថែមទៀតនៅក្នុងខេត្តទាំង ៥នេះ ដូចដែលបានប្រៀបធៀបទៅនឹងចំនួនគ្រួសារ។

## ៤.២. ចំនួនគ្រួសារក្នុង ១សហគ្រាសនៅកម្ពុជា គឺ ៦,២ គ្រួសារ

(យោងតារាង ៤.២, ក្រាហ្វ ៤.២ និងផែនទី ៤.២)

ខេត្តដែលមានគ្រួសារច្រើនជាងគេបំផុត គឺខេត្តឧត្តរមានជ័យ មាន ១០,០ គ្រួសារក្នុង ១ សហគ្រាស បន្ទាប់មកខេត្តស្វាយរៀង (៩,០) ខេត្តព្រៃវែង (៨,៧) ខេត្តកំពត (៨,៣) ខេត្តព្រះវិហារ (៧,៩)។ ខេត្តទាំង ៥ នេះមានគ្រួសារច្រើនក្នុង ១សហគ្រាស និងមានទីកន្លែងអាចបង្កើតអាជីវកម្មបានច្រើនបន្ថែមទៀត។

នៅក្នុងខណៈពេលនេះដែរ ខេត្តដែលមានគ្រួសារទាបបំផុតគិតក្នុង ១សហគ្រាស គឺរាជធានីភ្នំពេញ មាន៣,៦ គ្រួសារ បន្ទាប់មកគឺខេត្តកោះកុង (៤,៧) ខេត្តព្រះសីហនុ (៤,៨) ខេត្តកំពង់ឆ្នាំង (៤,៩) និងខេត្តប៉ៃលិន (៤,៩)។ ខេត្តទាំង ៥នេះ គឺស្ថិតភាគខាងលិច ឬនៅកណ្ដាលនៃប្រទេសកម្ពុជា និងស្ថិតនៅតំបន់វាលទំនាប ឬតំបន់ឆ្នេរសមុទ្រ។ ខេត្តទាំង៥នេះមានភាពប្រកួតប្រជែងខ្លាំងសម្រាប់ការងារអាជីវកម្ម។

## ៥. ចំនួនសហគ្រាសបានកើន ៥០ ៩១៥ ក្នុងអំឡុងឆ្នាំ ២០១១ ដល់២០១៤ នៅកម្ពុជា

(យោងតាមតារាង ៥, ក្រាហ្វិក៥.១, ផែនទី ៥.១និង៥.២)

រាជធានីភ្នំពេញមានកំណើនសហគ្រាសច្រើនជាងគេបំផុតក្នុងអំឡុងឆ្នាំ២០១១ ដល់២០១៤ ដែលមាន ១៣៩១៦សហគ្រាស បន្ទាប់មកគឺខេត្ត សៀមរាបមាន ៩៦៩៤សហគ្រាស ខេត្តកំពង់ឆ្នាំងមាន៤៣០២សហគ្រាស ខេត្តពោធិសាត់មាន៣៤៨០សហគ្រាស និងខេត្តតាកែវមាន២៩៦៥ សហគ្រាស នេះដោយសារតែសកម្មភាពអាជីវកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់ខេត្តទាំង៥នេះមានសភាពខ្លាំងខ្លា។

រាជធានីភ្នំពេញមានអាគារពាណិជ្ជកម្ម ផ្សារទំនើប ផ្ទះ និងផ្ទះល្វែងបានកើនឡើងគួរឲ្យកត់សម្គាល់ ហើយស្របពេលនេះដែរ ផ្នែកសំណង់បានរីករាលយ៉ាងឆាប់រហ័ស។ ក្រុមហ៊ុនបានពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់ពួកគេ ហើយបានបង្កើតនូវសាខាថែមទៀតផង។ បន្ថែមពីលើនេះទៀតទាំងភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិក៏បានកើនឡើងផងដែរ។

ខេត្តសៀមរាប សណ្ឋាគារ ផ្ទះសំណាក់ ភោគជនីយដ្ឋន ក្លឹបកំសាន្ត ម៉ាស្សា ហាងលក់ភេសជ្ជៈ និងហាងផ្សេងៗទៀតនៅក្នុងផ្សាររាត្រីបានកើនឡើង មិនតែប៉ុណ្ណោះ ទាំងភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិក៏បានកើនឡើងផងដែរ។ ផ្ទុយទៅវិញ អាជីវកម្មតាមចិញ្ចើមផ្លូវបានថយចុះនៅទីប្រជុំជន ហើយហាងលក់រាយ និងរោងម៉ាស៊ីនកិនស្រូវតូចៗក៏បានថយចុះនៅតំបន់ជនបទផងដែរ។

ខេត្តកំពង់ឆ្នាំងវិញ ទាំងរោងចក្រកាត់ដេរសំលៀកបំពាក់ និងរោងចក្រស្បែកជើង បានបើកដំណើរការថ្មីៗ ហើយបានផ្តល់នូវឱកាសការងារជាច្រើនដល់ទីផ្សារពលកម្ម។

ខេត្តពោធិសាត់មាន រោងចក្រខ្នាតធំ២ ដែលបានបង្កើតឡើងនៅក្នុងស្រុកក្រគរ មួយគឺរោងចក្រកាត់ដេរសំលៀកបំពាក់ និងមួយទៀតគឺក្រុមហ៊ុនកិនស្រូវដែលមានលទ្ធភាពនាំចេញអង្ករទៅទីផ្សារអន្តរជាតិ។ ជាទូទៅអាជីវកម្មតូចបានកើនឡើងដោយសាមានការអភិវឌ្ឍន៍ទីក្រុង។

ខេត្តកំពង់ចាមវិញ ធនាគារ និងអាជីវកម្មដឹកជញ្ជូនបានកើនឡើង លើសពីនេះទៀត មានសណ្ឋាគារ ភោគជនីយដ្ឋាន យាន្តដ្ឋាន និងហាងលក់ស៊ីបង្គចក៏កើនឡើងដែរ។

ខេត្តក្រចេះវិញ អាជីវកម្មលក់ដុំ និងលក់រាយ សណ្ឋាគារ ភោគជនីយដ្ឋាន បានកើនឡើងដោយសាតែមានកំណើនភ្ញៀវទេសចរ។

ខេត្តបាត់ដំបងវិញអាជីវកម្មលក់រាយ សណ្ឋាគារ និងផ្ទះសំណាក់បានកើនឡើងនៅតំបន់ទីប្រជុំជន លើសពីនេះមានផ្សារ ផ្ទះធំៗ និងផ្ទះល្វែងបានសាងសង់ថ្មីៗ។ សាខាការិយាល័យមួយចំនួនក៏បានដំណើការផងដែរ ដែលទីស្នាក់ការកណ្តាលរបស់វានៅរាជធានីភ្នំពេញ។ កំណើនភ្ញៀវទេសចរគឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលជាមូលហេតុនាំឲ្យមានសហគ្រាស អាជីវកម្មកើនឡើង ម្យ៉ាងវិញទៀតសហគ្រាសខ្នាតមីក្រូបានធ្លាក់ចុះដោយសារតែមានការធ្វើអន្តោប្រវេសន៍ទៅខេត្តផ្សេងៗ ឬទៅប្រទេសថៃរកការងារធ្វើ។ លើពីនេះអាកប្បកិរិយារបស់អ្នកឡើងផ្សារទិញមានការប្រែប្រួល ពួកគាត់បានប្តូរទៅទិញទំនិញ ឬផលិតផលនៅតាមផ្សារ ឬហាងធំៗវិញ ដូច្នេះហើយអាជីវកម្មប្រភេទមីក្រូបានធ្លាក់ចុះ។

ខេត្តកណ្តាលវិញ កំពង់ផែភ្នំពេញត្រូវបានក៏សាងជាថ្មី ដែលនាំឲ្យមានកំណើនសហគ្រាសតិចតួច បើទោះបីជាមានការបាត់បង់នូវឃុំចំនួន២០របស់វា ដោយបានកាត់ចេញនៅឆ្នាំ២០១០ក៏ដោយ។ ពាណិជ្ជកម្មលក់ដុំ និងលក់រាយគឺមានកំណើនច្រើន បន្ថែមពីលើនេះទៀត ស្ពានព្រែកតាម៉ាក់ឆ្លងកាត់ទន្លេមេគង្គ និងស្ពានព្រែកក្តាម ឆ្លងកាត់ទន្លេបាសាក់ហាក់បីដូចជាមានឥទ្ធិពលមួយដល់កំណើនសហគ្រាសដែរ ប៉ុន្តែសហគ្រាសផ្នែករ៉ែបានថយចុះទៅវិញនៅខេត្តកណ្តាល។

ខេត្តព្រះសីហនុ រោងចក្រតម្បាញ សណ្ឋាគារ ផ្ទះសំណាក់ និងភោគជនីយដ្ឋានបាន កើនឡើង។

ខេត្តកំពត ផ្ទះសំណាក់ និងភោគជនីយដ្ឋានបានកើនឡើងគួរឲ្យកត់សម្គាល់។

ខេត្តកំពង់ស្ពឺ រោងចក្រកាត់ដេរសម្លៀកបំពាក់បានកើនឡើង ប៉ុន្តែអាជីវកម្មតូចៗបានថយចុះនៅតាមជនបទ។

ខេត្តឧត្តរមានជ័យ ថ្មីៗនេះកាស៊ីណូថ្មីមួយបានសាងសង់ ច្រកការិយាល័យអន្តោប្រវេសន៍អន្តរជាតិក៏បានបើកដំណើរការ ហើយអាជីវកម្មតូចៗក៏បានកើនឡើងដែរ។

ខេត្តប៉ៃលិន អាជីវកម្មមីក្រូបានកើនឡើង។

ទន្ទឹមគ្នានេះដែរ ខេត្តដែលកើនចំនួនសហគ្រាសតិចជាងគេគឺខេត្តកែប ដែលកើនចំនួន ១៣៩ សហគ្រាស បន្ទាប់មកគឺខេត្តស្ទឹងត្រែង កើន ១៩៦សហគ្រាស ខេត្តប៉ៃលិនកើន ២៩១សហគ្រាស ខេត្តកំពង់ធំកើន ៣៧៣សហគ្រាស និងមណ្ឌលគីរីកើន ៣៩៩ សហគ្រាស។ បណ្តាខេត្តទាំងនេះហាក់ដូចជាមានឱកាសសម្រាប់វិនិយោគនៅក្នុងខេត្តទាំងនេះ លើកលែងតែខេត្តកែបចេញ។

ខេត្តកោះកុង បានថយចុះអាជីវកម្មតូចៗនៅតំបន់ជនបទ ហាក់បីដូចថាម្ចាស់អាជីវកម្មទាំងនោះបានបោះបង់ចោលនូវអាជីវកម្មរបស់ពួកគាត់ ហើយចាប់ផ្តើមធ្វើការនៅរោងចក្រ ឬនៅតាមសហគ្រាសខ្នាតធំវិញ។

# ផ្នែក២
# ផែនទី និង ក្រាហ្វិក

* លទ្ធផលបឋមនេះផ្អែកលើតំបន់រដ្ឋបាលថ្មីដែលបានដាក់អោយប្រើប្រាស់នៅថ្ងៃទី៥ ខែ វិច្ឆិកា ឆ្នាំ ២០១០។

** លទ្ធផលបឋមនេះមានបំណងផ្សព្វផ្សាយមុន នូវចំនួនសហគ្រាស ហើយ លទ្ធផលនេះអាចមានភាពខុសគ្នាបន្តិចបន្តួចពីលទ្ធផលចុងក្រោយដែលនឹងត្រូវផ្សព្វផ្សាយនូវខែ កុម្ភៈ ឆ្នាំ ២០១៥។

## ក្រាហ្វិក១. ភាគរយនៃចំនួនសហគ្រាសសរុបបែងចែកតាមរាជធានី ខេត្ត ឆ្នាំ ២០១៤ និង ភាគរយនៃចំនួនប្រជារាស្ត្រសរុបបែងចែកតាមរាជធានី ខេត្ត ឆ្នាំ ២០១៤




សំគាល់: លទ្ធផលចុងក្រោយនៃអង្កេតចន្លោះជំរឿនប្រជារាស្ត្រទូទៅកម្ពុជាឆ្នាំ២០១៣ត្រូវបានប្រើប្រាស់ ជាទិន្នន័យមូលដ្ឋានស្ថិតិប្រជារាស្ត្រនៅក្នុងក្រាហ្វិកខាងលើនេះ។

## ក្រាហ្វិក២. ដង់ស៊ីតេសហគ្រាស បែងចែកតាមរាជធានី ខេត្តឆ្នាំ ២០១៤



## ក្រាហ្វិក៣.១ ចំនួនសហគ្រាសក្នុងប្រជារាស្ត្រ១០០០នាក់ បែងចែកតាមរាជធានី ខេត្ត ឆ្នាំ ២០១៤




សំគាល់: លទ្ធផលចុងក្រោយនៃអង្កេតចន្លោះជំរឿនប្រជារាស្ត្រទូទៅកម្ពុជាឆ្នាំ២០១៣ត្រូវបានប្រើប្រាស់ ជាទិន្នន័យមូលដ្ឋានស្ថិតិប្រជារាស្ត្រនៅក្នុងក្រាហ្វិកខាងលើនេះ។

## ក្រាហ្វិក៣.២. ចំនួនប្រជារាស្ត្រក្នុងមួយសហគ្រាសបែងចែកតាមរាជធានី ខេត្តឆ្នាំ ២០១៤




សំគាល់: លទ្ធផលចុងក្រោយនៃអង្កេតចន្លោះជំរឿនប្រជារាស្ត្រទូទៅកម្ពុជាឆ្នាំ២០១៣ត្រូវបានប្រើប្រាស់ ជាទិន្នន័យមូលដ្ឋានស្ថិតិប្រជារាស្ត្រនៅក្នុងក្រាហ្វិកខាងលើនេះ។

## ក្រាហ្វិក៤.១ ចំនួនសហគ្រាសក្នុង១០០០ គ្រួសារធម្មតាបែងចែកតាមរាជធានី ខេត្ត ឆ្នាំ ២០១៤




សំគាល់: លទ្ធផលចុងក្រោយនៃអង្កេតចន្លោះជំរឿនប្រជារាស្ត្រទូទៅកម្ពុជាឆ្នាំ២០១៣ត្រូវបានប្រើប្រាស់ ជាទិន្នន័យមូលដ្ឋានស្ថិតិប្រជារាស្ត្រនៅក្នុងក្រាហ្វិកខាងលើនេះ។

## ក្រាហ្វិក៤.២. ចំនួនគ្រួសារធម្មតាក្នុងមួយសហគ្រាសបែងចែកតាមរាជធានី ខេត្ត ឆ្នាំ ២០១៤




សំគាល់: លទ្ធផលចុងក្រោយនៃអង្កេតចន្លោះជំរឿនប្រជារាស្ត្រទូទៅកម្ពុជាឆ្នាំ២០១៣ត្រូវបានប្រើប្រាស់ ជាទិន្នន័យមូលដ្ឋានស្ថិតិប្រជារាស្ត្រនៅក្នុងក្រាហ្វិកខាងលើនេះ។

## ក្រាហ្វិក៥.១ កំណើនសហគ្រាស បែងចែកតាមរាជធានី ខេត្ត ឆ្នាំ ២០១១-២០១៤



## ក្រាហ្វិក៥.២ អត្រាកំណើនសហគ្រាសបែងចែកតាមរាជធានី ខេត្ត ឆ្នាំ ២០១១-២០១៤



# ផែនទី ១. តួលេខបណ្តោះអាសន្ននៃចំនួនសហគ្រាស បែងចែកតាមខេត្ត ឆ្នាំ ២០១៤



ផែនទី ២. តួលេខបណ្ដោះអាសន្ននៃដង់ស៊ីតេសហគ្រាស បែងចែកតាមខេត្ត ឆ្នាំ ២០១៤



ផែនទី ៣-១. តួលេខបណ្ដោះអាសន្ននៃចំនួនសហគ្រាសក្នុងមនុស្ស ១.០០០នាក់ បែងចែកតាមខេត្ត ឆ្នាំ ២០១៤



## ផែនទី ៣-២. តួលេខបណ្ដោះអាសន្ននៃចំនួនមនុស្សក្នុង ១សហគ្រាស បែងចែកតាមខេត្ត ឆ្នាំ ២០១៤



ផែនទី ៤-១. តួលេខបណ្តោះអាសន្ននៃចំនួនសហគ្រាសក្នុង ១.០០០គ្រួសារធម្មតា បែងចែកតាមខេត្ត ឆ្នាំ ២០១៤



ផែនទី ៤-២. តួលេខបណ្តោះអាសន្ននៃចំនួនគ្រួសារធម្មតាក្នុង ១សហគ្រាស បែងចែកតាមខេត្ត ឆ្នាំ ២០១៤



ផែនទី ៥-១. តួលេខបណ្ដោះអាសន្ននៃកំណើនចំនួនសហគ្រាស ក្នុងកំឡុងឆ្នាំ ២០១១ ដល់ ២០១៤ បែងចែកតាមខេត្ត



ផែនទី ៥-២. តួលេខបណ្តោះអាសន្ននៃអត្រាកំណើនសហគ្រាស ក្នុងកំឡុងឆ្នាំ ២០១១ ដល់ ២០១៤ បែងចែកតាមខេត្ត



# ផ្នែក៣

# តារាងស្ថិត

* លទ្ធផលបឋមនេះផ្អែកលើតំបន់រដ្ឋបាលថ្មីដែលបានដាក់អោយប្រើប្រាស់នៅថ្ងៃទី៥ ខែ វិច្ឆិកា ឆ្នាំ ២០១០។

** លទ្ធផលបឋមនេះមានបំណងផ្សព្វផ្សាយមុន នូវចំនួនសហគ្រាស ហើយ លទ្ធផលនេះអាចមានភាពខុសគ្នាបន្តិចបន្តួចពីលទ្ធផលចុងក្រោយដែលនឹងត្រូវ ផ្សព្វផ្សាយនូវខែ កុម្ភៈ ឆ្នាំ ២០១៥។

*** សហគ្រាសតាមចិញ្ចើមផ្លូវត្រូវបានដកចេញ ពីព្រោះសហគ្រាសនេះមិនបានធ្វើ សម្ភាសន៍ទេ

តារាង ១. ចំនួនសហគ្រាស, ភាគរយនៃចំនួនសហគ្រាសសរុប និងលំដាប់ថ្នាក់បែងចែកតាម
រាជធានី ខេត្ត ឆ្នាំ ២០១៤

| លរ | រាជធានី ខេត្ត | ចំនួនសហគ្រាសឆ្នាំ ២០១៤ ១) (សហគ្រាស) | ភាគរយនៃចំនួនសហគ្រាសសរុប (%) | លំដាប់ | ចំនួនប្រជារាស្ត្រឆ្នាំ ២០១៣ ២) (នាក់) | ភាគរយនៃចំនួនប្រជារាស្ត្រសរុប (%) | លំដាប់ |
|---|---|---|---|---|---|---|---|
| | **កម្ពុជា** | **514,278** | **100.0** | | **14,676,591** | **100.0** | |
| 01 | បន្ទាយមានជ័យ | 21,546 | 4.2 | 10 | 729,569 | 5.0 | 9 |
| 02 | បាត់ដំបង | 32,515 | 6.3 | 6 | 1,121,019 | 7.6 | 4 |
| 03 | កំពង់ចាម | 54,229 | 10.5 | 2 | 1,757,223 | 12.0 | 1 |
| 04 | កំពង់ឆ្នាំង | 22,827 | 4.4 | 8 | 523,202 | 3.6 | 13 |
| 05 | កំពង់ស្ពឺ | 22,258 | 4.3 | 9 | 755,465 | 5.1 | 8 |
| 06 | កំពង់ធំ | 21,006 | 4.1 | 11 | 690,414 | 4.7 | 10 |
| 07 | កំពត | 16,456 | 3.2 | 12 | 611,557 | 4.2 | 11 |
| 08 | កណ្ដាល | 38,664 | 7.5 | 3 | 1,115,965 | 7.6 | 5 |
| 09 | កោះកុង | 5,452 | 1.1 | 19 | 122,263 | 0.8 | 21 |
| 10 | ក្រចេះ | 12,157 | 2.4 | 15 | 344,195 | 2.3 | 15 |
| 11 | មណ្ឌលគិរី | 2,594 | 0.5 | 23 | 72,680 | 0.5 | 22 |
| 12 | ភ្នំពេញ | 98,646 | 19.2 | 1 | 1,688,044 | 11.5 | 2 |
| 13 | ព្រះវិហារ | 6,136 | 1.2 | 17 | 235,370 | 1.6 | 17 |
| 14 | ព្រៃវែង | 29,521 | 5.7 | 7 | 1,156,739 | 7.9 | 3 |
| 15 | ពោធិ៍សាត់ | 14,270 | 2.8 | 14 | 435,596 | 3.0 | 14 |
| 16 | រតនគិរី | 6,095 | 1.2 | 18 | 183,699 | 1.3 | 19 |
| 17 | សៀមរាប | 37,617 | 7.3 | 4 | 922,982 | 6.3 | 7 |
| 18 | ព្រះសីហនុ | 10,789 | 2.1 | 16 | 250,180 | 1.7 | 16 |
| 19 | ស្ទឹងត្រែង | 4,608 | 0.9 | 21 | 122,791 | 0.8 | 20 |
| 20 | ស្វាយរៀង | 14,521 | 2.8 | 13 | 578,380 | 3.9 | 12 |
| 21 | តាកែវ | 32,778 | 6.4 | 5 | 923,373 | 6.3 | 6 |
| 22 | ឧត្ដរមានជ័យ | 5,042 | 1.0 | 20 | 231,390 | 1.6 | 18 |
| 23 | កែប | 1,607 | 0.3 | 24 | 38,701 | 0.3 | 24 |
| 24 | ប៉ៃលិន | 2,945 | 0.6 | 22 | 65,795 | 0.4 | 23 |

១) សហគ្រាសតាមចញ្ចើមផ្លូវត្រូវបានដកចេញពីព្រោះសហគ្រាសនេះមិនបានសម្ភាសន៍ទេ
២) យោងតាមតារាង ៣.២ , របាយការណ៍ចុងក្រោយ, នៃអង្កេតចន្លោះជំរឿនប្រជាពលរដ្ឋទូទៅកម្ពុជាឆ្នាំ ២០១៣

តារាង២. ដង់ស៊ីតេសហគ្រាស និង លំដាប់ បែងចែកតាមរាជធានី ខេត្តឆ្នាំ២០១៤

| លរ | រាជធានី ខេត្ត | ចំនួន សហគ្រាស ឆ្នាំ ២០១៤ ១) (សហគ្រាស) | ផ្ទៃក្រឡាឆ្នាំ ២០១០ ២) (គីឡូម៉ែត្រការ៉េ) | ដង់ស៊ីតេសហគ្រាសឆ្នាំ ២០១៤ (សហគ្រាស/គីឡូម៉ែត្រការ៉េ) | លំដាប់ | ដង់ស៊ីតេប្រជារាស្ត្រឆ្នាំ ២០១៣ ៣) (នាក់/គីឡូម៉ែត្រការ៉េ) | លំដាប់ |
|---|---|---|---|---|---|---|---|
| | **កម្ពុជា** | **514,278** | **181,035** | **2.8** | | **81** | |
| 01 | បន្ទាយមានជ័យ | 21,546 | 6,679 | 3.2 | 13 | 109 | 10 |
| 02 | បាត់ដំបង | 32,515 | 11,702 | 2.8 | 15 | 96 | 12 |
| 03 | កំពង់ចាម | 54,229 | 9,799 | 5.5 | 6 | 179 | 6 |
| 04 | កំពង់ឆ្នាំង | 22,827 | 5,521 | 4.1 | 9 | 95 | 13 |
| 05 | កំពង់ស្ពឺ | 22,258 | 7,017 | 3.2 | 14 | 108 | 11 |
| 06 | កំពង់ធំ | 21,006 | 13,814 | 1.5 | 16 | 50 | 16 |
| 07 | កំពត | 16,456 | 4,873 | 3.4 | 12 | 125 | 8 |
| 08 | កណ្តាល | 38,664 | 3,255 | 11.9 | 2 | 343 | 2 |
| 09 | កោះកុង | 5,452 | 10,090 | 0.5 | 21 | 12 | 22 |
| 10 | ក្រចេះ | 12,157 | 11,094 | 1.1 | 18 | 31 | 19 |
| 11 | មណ្ឌលគិរី | 2,594 | 14,288 | 0.2 | 24 | 5 | 24 |
| 12 | ភ្នំពេញ | 98,646 | 603 | 163.6 | 1 | 2,799 | 1 |
| 13 | ព្រះវិហារ | 6,136 | 13,788 | 0.4 | 22 | 17 | 20 |
| 14 | ព្រៃវែង | 29,521 | 4,883 | 6.0 | 4 | 237 | 4 |
| 15 | ពោធិ៍សាត់ | 14,270 | 12,692 | 1.1 | 17 | 34 | 18 |
| 16 | រតនគិរី | 6,095 | 10,782 | 0.6 | 20 | 17 | 21 |
| 17 | សៀមរាប | 37,617 | 10,299 | 3.7 | 11 | 90 | 14 |
| 18 | ព្រះសីហនុ | 10,789 | 1,938 | 5.6 | 5 | 129 | 7 |
| 19 | ស្ទឹងត្រែង | 4,608 | 11,092 | 0.4 | 23 | 11 | 23 |
| 20 | ស្វាយរៀង | 14,521 | 2,966 | 4.9 | 7 | 195 | 5 |
| 21 | តាកែវ | 32,778 | 3,563 | 9.2 | 3 | 259 | 3 |
| 22 | ឧត្តរមានជ័យ | 5,042 | 6,158 | 0.8 | 19 | 38 | 17 |
| 23 | កែប | 1,607 | 336 | 4.8 | 8 | 115 | 9 |
| 24 | ប៉ៃលិន | 2,945 | 803 | 3.7 | 10 | 82 | 15 |

១) សម្រាប់ចំនួនសហគ្រាស, យោងតាម១) តារាង១

២) ផ្ទៃក្រឡាយោងតាមតួលេខចេញផ្សាយដោយក្រសួងមហាផ្ទៃក្នុងឆ្នាំ ២០០៨ លើកលែងតំបន់ដូចខាងក្រោម:
ផ្ទៃក្រឡារាជធានីភ្នំពេញ និងខេត្តកណ្តាលត្រូវបានប៉ាន់ស្មានជាបណ្តោះអាសន្នដោយក្រសួងផែនការ
ដោយសារតែការប្រែប្រួលព្រំប្រទល់តំបន់រដ្ឋបាលនៅថ្ងៃទី ៥ វិច្ឆិកា ឆ្នាំ ២០១០។
ផ្ទៃក្រឡានៃព្រះរាជាណាចក្រកម្ពុជារួមបញ្ចូលផ្ទៃក្រឡាបឹងទន្លេសាប ( ៣០០០ គីឡូម៉ែត្រការ៉េ)

៣) សម្រាប់ប្រជារាស្ត្រ យោងតាម ២) តារាង១

## តារាង៣-១. ចំនួនសហគ្រាសក្នុងប្រជារាស្ត្រ១០០០នាក់ បែងចែកតាមរាជធានី ខេត្តឆ្នាំ២០១៤

| លរ | រាជធានី ខេត្ត | ចំនួនសហគ្រាសឆ្នាំ ២០១៤ ១) (សហគ្រាស) | ចំនួនប្រជារាស្ត្រឆ្នាំ ២០១៣ ២) (នាក់) | ចំនួនសហគ្រាសក្នុងប្រជារាស្រ១០០០ នាក់ឆ្នាំ២០១៤ (សហគ្រាស) | លំដាប់ | ដង់ស៊ីតេ សហគ្រាស ឆ្នាំ២០១៤ ៣) (សហគ្រាស/គីឡូម៉ែត្រការ៉េ) | លំដាប់ |
|---|---|---|---|---|---|---|---|
| | **កម្ពុជា** | **514,278** | **14,676,591** | **35.0** | | **2.8** | |
| 01 | បន្ទាយមានជ័យ | 21,546 | 729,569 | 29.5 | 17 | 3.2 | 13 |
| 02 | បាត់ដំបង | 32,515 | 1,121,019 | 29.0 | 19 | 2.8 | 15 |
| 03 | កំពង់ចាម | 54,229 | 1,757,223 | 30.9 | 15 | 5.5 | 6 |
| 04 | កំពង់ឆ្នាំង | 22,827 | 523,202 | 43.6 | 4 | 4.1 | 9 |
| 05 | កំពង់ស្ពឺ | 22,258 | 755,465 | 29.5 | 18 | 3.2 | 14 |
| 06 | កំពង់ធំ | 21,006 | 690,414 | 30.4 | 16 | 1.5 | 16 |
| 07 | កំពត | 16,456 | 611,557 | 26.9 | 20 | 3.4 | 12 |
| 08 | កណ្ដាល | 38,664 | 1,115,965 | 34.6 | 12 | 11.9 | 2 |
| 09 | កោះកុង | 5,452 | 122,263 | 44.6 | 3 | 0.5 | 21 |
| 10 | ក្រចេះ | 12,157 | 344,195 | 35.3 | 11 | 1.1 | 18 |
| 11 | មណ្ឌលគិរី | 2,594 | 72,680 | 35.7 | 9 | 0.2 | 24 |
| 12 | ភ្នំពេញ | 98,646 | 1,688,044 | 58.4 | 1 | 163.6 | 1 |
| 13 | ព្រះវិហារ | 6,136 | 235,370 | 26.1 | 21 | 0.4 | 22 |
| 14 | ព្រៃវែង | 29,521 | 1,156,739 | 25.5 | 22 | 6.0 | 4 |
| 15 | ពោធិ៍សាត់ | 14,270 | 435,596 | 32.8 | 14 | 1.1 | 17 |
| 16 | រតនគិរី | 6,095 | 183,699 | 33.2 | 13 | 0.6 | 20 |
| 17 | សៀមរាប | 37,617 | 922,982 | 40.8 | 7 | 3.7 | 11 |
| 18 | ព្រះសីហនុ | 10,789 | 250,180 | 43.1 | 5 | 5.6 | 5 |
| 19 | ស្ទឹងត្រែង | 4,608 | 122,791 | 37.5 | 8 | 0.4 | 23 |
| 20 | ស្វាយរៀង | 14,521 | 578,380 | 25.1 | 23 | 4.9 | 7 |
| 21 | តាកែវ | 32,778 | 923,373 | 35.5 | 10 | 9.2 | 3 |
| 22 | ឧត្តរមានជ័យ | 5,042 | 231,390 | 21.8 | 24 | 0.8 | 19 |
| 23 | កែប | 1,607 | 38,701 | 41.5 | 6 | 4.8 | 8 |
| 24 | ប៉ៃលិន | 2,945 | 65,795 | 44.8 | 2 | 3.7 | 10 |

១) សម្រាប់ចំនួនសហគ្រាស, យោងតាម១) តារាង១

២) សម្រាប់ប្រជារាស្ត្រ យោងតាម ២) តារាង១

៣) សម្រាប់ផ្ទៃក្រឡា យោងតាម ២) នៅតារាង២

## តារាង៣-២. ចំនួនប្រជារាស្ត្រក្នុងមួយសហគ្រាសបែងចែកតាមរាជធានី ខេត្តឆ្នាំ២០១៤

| លរ | រាជធានី ខេត្ត | ចំនួនសហគ្រាសឆ្នាំ ២០១៤ ១) (សហគ្រាស) | ចំនួនប្រជារាស្ត្រឆ្នាំ ២០១៣ ២) (នាក់) | ចំនួនប្រជារាស្ត្រក្នុងមួយសហគ្រាសឆ្នាំ ២០១៤ (នាក់) | លំដាប់ | ដង់ស៊ីតេប្រជារាស្ត្រ ឆ្នាំ ២០១៣ ៣) (នាក់/គីឡូម៉ែត្រការ៉េ) | លំដាប់ |
|---|---|---|---|---|---|---|---|
| | **កម្ពុជា** | **514,278** | **14,676,591** | **28.5** | | **81** | |
| 01 | បន្ទាយមានជ័យ | 21,546 | 729,569 | 33.9 | 8 | 109 | 10 |
| 02 | បាត់ដំបង | 32,515 | 1,121,019 | 34.5 | 6 | 96 | 12 |
| 03 | កំពង់ចាម | 54,229 | 1,757,223 | 32.4 | 10 | 179 | 6 |
| 04 | កំពង់ឆ្នាំង | 22,827 | 523,202 | 22.9 | 21 | 95 | 13 |
| 05 | កំពង់ស្ពឺ | 22,258 | 755,465 | 33.9 | 7 | 108 | 11 |
| 06 | កំពង់ធំ | 21,006 | 690,414 | 32.9 | 9 | 50 | 16 |
| 07 | កំពត | 16,456 | 611,557 | 37.2 | 5 | 125 | 8 |
| 08 | កណ្ដាល | 38,664 | 1,115,965 | 28.9 | 13 | 343 | 2 |
| 09 | កោះកុង | 5,452 | 122,263 | 22.4 | 22 | 12 | 22 |
| 10 | ក្រចេះ | 12,157 | 344,195 | 28.3 | 14 | 31 | 19 |
| 11 | មណ្ឌលគិរី | 2,594 | 72,680 | 28.0 | 16 | 5 | 24 |
| 12 | ភ្នំពេញ | 98,646 | 1,688,044 | 17.1 | 24 | 2,799 | 1 |
| 13 | ព្រះវិហារ | 6,136 | 235,370 | 38.4 | 4 | 17 | 20 |
| 14 | ព្រៃវែង | 29,521 | 1,156,739 | 39.2 | 3 | 237 | 4 |
| 15 | ពោធិ៍សាត់ | 14,270 | 435,596 | 30.5 | 11 | 34 | 18 |
| 16 | រតនគិរី | 6,095 | 183,699 | 30.1 | 12 | 17 | 21 |
| 17 | សៀមរាប | 37,617 | 922,982 | 24.5 | 18 | 90 | 14 |
| 18 | ព្រះសីហនុ | 10,789 | 250,180 | 23.2 | 20 | 129 | 7 |
| 19 | ស្ទឹងត្រែង | 4,608 | 122,791 | 26.6 | 17 | 11 | 23 |
| 20 | ស្វាយរៀង | 14,521 | 578,380 | 39.8 | 2 | 195 | 5 |
| 21 | តាកែវ | 32,778 | 923,373 | 28.2 | 15 | 259 | 3 |
| 22 | ឧត្ដរមានជ័យ | 5,042 | 231,390 | 45.9 | 1 | 38 | 17 |
| 23 | កែប | 1,607 | 38,701 | 24.1 | 19 | 115 | 9 |
| 24 | ប៉ៃលិន | 2,945 | 65,795 | 22.3 | 23 | 82 | 15 |

១) សម្រាប់ចំនួនសហគ្រាស, យោងតាម១) តារាង១

២) សម្រាប់ប្រជារាស្ត្រ យោងតាម ២) តារាង១

៣) សម្រាប់ផ្ទៃក្រឡា យោងតាម ២) នៅតារាង២

តារាង៤-១. ចំនួនសហគ្រាសក្នុង១០០០គ្រួសារធម្មតា បែងចែកតាមរាជធានី ខេត្តឆ្នាំ២០១៤

| លរ | រាជធានី ខេត្ត | ចំនួនសហគ្រាសឆ្នាំ ២០១៤ ១) (សហគ្រាស) | ចំនួនគ្រួសារធម្មតាឆ្នាំ ២០១៣ ២) (គ្រួសារ) | ចំនួនសហគ្រាសក្នុង ១០០០គ្រួសារធម្មតាឆ្នាំ២០១៤ (សហគ្រាស) | លំដាប់ | ចំនួនសហគ្រាសក្នុងប្រជាពលរដ្ឋ ១០០០នាក់ ឆ្នាំ២០១៤ ៣) (សហគ្រាស) | លំដាប់ |
|---|---|---|---|---|---|---|---|
| | **កម្ពុជា** | **514,278** | **3,163,226** | **162.6** | | **35.0** | |
| 01 | បន្ទាយមានជ័យ | 21,546 | 161,423 | 133.5 | 19 | 29.5 | 17 |
| 02 | បាត់ដំបង | 32,515 | 230,304 | 141.2 | 15 | 29.0 | 19 |
| 03 | កំពង់ចាម | 54,229 | 403,628 | 134.4 | 18 | 30.9 | 15 |
| 04 | កំពង់ឆ្នាំង | 22,827 | 111,355 | 205.0 | 4 | 43.6 | 4 |
| 05 | កំពង់ស្ពឺ | 22,258 | 157,982 | 140.9 | 16 | 29.5 | 18 |
| 06 | កំពង់ធំ | 21,006 | 149,404 | 140.6 | 17 | 30.4 | 16 |
| 07 | កំពត | 16,456 | 136,148 | 120.9 | 21 | 26.9 | 20 |
| 08 | កណ្តាល | 38,664 | 238,435 | 162.2 | 13 | 34.6 | 12 |
| 09 | កោះកុង | 5,452 | 25,658 | 212.5 | 2 | 44.6 | 3 |
| 10 | ក្រចេះ | 12,157 | 73,050 | 166.4 | 11 | 35.3 | 11 |
| 11 | មណ្ឌលគិរី | 2,594 | 15,251 | 170.1 | 9 | 35.7 | 9 |
| 12 | ភ្នំពេញ | 98,646 | 352,702 | 279.7 | 1 | 58.4 | 1 |
| 13 | ព្រះវិហារ | 6,136 | 48,242 | 127.2 | 20 | 26.1 | 21 |
| 14 | ព្រៃវែង | 29,521 | 255,960 | 115.3 | 22 | 25.5 | 22 |
| 15 | ពោធិ៍សាត់ | 14,270 | 96,284 | 148.2 | 14 | 32.8 | 14 |
| 16 | រតនគិរី | 6,095 | 36,178 | 168.5 | 10 | 33.2 | 13 |
| 17 | សៀមរាប | 37,617 | 189,708 | 198.3 | 6 | 40.8 | 7 |
| 18 | ព្រះសីហនុ | 10,789 | 51,955 | 207.7 | 3 | 43.1 | 5 |
| 19 | ស្ទឹងត្រែង | 4,608 | 25,359 | 181.7 | 8 | 37.5 | 8 |
| 20 | ស្វាយរៀង | 14,521 | 130,972 | 110.9 | 23 | 25.1 | 23 |
| 21 | តាកែវ | 32,778 | 200,099 | 163.8 | 12 | 35.5 | 10 |
| 22 | ឧត្តរមានជ័យ | 5,042 | 50,266 | 100.3 | 24 | 21.8 | 24 |
| 23 | កែប | 1,607 | 8,378 | 191.8 | 7 | 41.5 | 6 |
| 24 | ប៉ៃលិន | 2,945 | 14,483 | 203.3 | 5 | 44.8 | 2 |

១) សម្រាប់ចំនួនសហគ្រាស, យោងតាម១) តារាង១

២) យោងតាមតារាង ២.២ ,របាយការណ៍វិភាគ លេខ ១០, នៃអង្កេតចន្លោះជំរឿនប្រជាពលរដ្ឋទូទៅកម្ពុជាឆ្នាំ ២០១៣

៣) សម្រាប់ប្រជាពលរដ្ឋ យោងតាម ២) នៅតារាង១

### តារាង៤-២. ចំនួនគ្រួសារធម្មតាក្នុងមួយសហគ្រាសបែងចែកតាមរាជធានី ខេត្តឆ្នាំ២០១៤

| លរ | រាជធានី ខេត្ត | ចំនួនសហគ្រាសឆ្នាំ ២០១៤ ១) (សហគ្រាស) | ចំនួនគ្រួសារធម្មតាឆ្នាំ ២០១៣ ២) (គ្រួសារ) | ចំនួនគ្រួសារធម្មតាក្នុងមួយសហគ្រាសឆ្នាំ ២០១៤ (គ្រួសារ) | លំដាប់ | ចំនួនប្រជារាស្ត្រក្នុងមួយសហគ្រាសឆ្នាំ ២០១៤ ៣) (នាក់) | លំដាប់ |
|---|---|---|---|---|---|---|---|
| | **កម្ពុជា** | **514,278** | **3,163,226** | **6.2** | | **28.5** | |
| 01 | បន្ទាយមានជ័យ | 21,546 | 161,423 | 7.5 | 6 | 33.9 | 8 |
| 02 | បាត់ដំបង | 32,515 | 230,304 | 7.1 | 10 | 34.5 | 6 |
| 03 | កំពង់ចាម | 54,229 | 403,628 | 7.4 | 7 | 32.4 | 10 |
| 04 | កំពង់ឆ្នាំង | 22,827 | 111,355 | 4.9 | 21 | 22.9 | 21 |
| 05 | កំពង់ស្ពឺ | 22,258 | 157,982 | 7.1 | 9 | 33.9 | 7 |
| 06 | កំពង់ធំ | 21,006 | 149,404 | 7.1 | 8 | 32.9 | 9 |
| 07 | កំពត | 16,456 | 136,148 | 8.3 | 4 | 37.2 | 5 |
| 08 | កណ្តាល | 38,664 | 238,435 | 6.2 | 12 | 28.9 | 13 |
| 09 | កោះកុង | 5,452 | 25,658 | 4.7 | 23 | 22.4 | 22 |
| 10 | ក្រចេះ | 12,157 | 73,050 | 6.0 | 14 | 28.3 | 14 |
| 11 | មណ្ឌលគិរី | 2,594 | 15,251 | 5.9 | 16 | 28.0 | 16 |
| 12 | ភ្នំពេញ | 98,646 | 352,702 | 3.6 | 24 | 17.1 | 24 |
| 13 | ព្រះវិហារ | 6,136 | 48,242 | 7.9 | 5 | 38.4 | 4 |
| 14 | ព្រៃវែង | 29,521 | 255,960 | 8.7 | 3 | 39.2 | 3 |
| 15 | ពោធិ៍សាត់ | 14,270 | 96,284 | 6.7 | 11 | 30.5 | 11 |
| 16 | រតនគិរី | 6,095 | 36,178 | 5.9 | 15 | 30.1 | 12 |
| 17 | សៀមរាប | 37,617 | 189,708 | 5.0 | 19 | 24.5 | 18 |
| 18 | ព្រះសីហនុ | 10,789 | 51,955 | 4.8 | 22 | 23.2 | 20 |
| 19 | ស្ទឹងត្រែង | 4,608 | 25,359 | 5.5 | 17 | 26.6 | 17 |
| 20 | ស្វាយរៀង | 14,521 | 130,972 | 9.0 | 2 | 39.8 | 2 |
| 21 | តាកែវ | 32,778 | 200,099 | 6.1 | 13 | 28.2 | 15 |
| 22 | ឧត្តរមានជ័យ | 5,042 | 50,266 | 10.0 | 1 | 45.9 | 1 |
| 23 | កែប | 1,607 | 8,378 | 5.2 | 18 | 24.1 | 19 |
| 24 | ប៉ៃលិន | 2,945 | 14,483 | 4.9 | 20 | 22.3 | 23 |

១) សម្រាប់ចំនួនសហគ្រាស, យោងតាម១) តារាង១

២) សម្រាប់ចំនួនគ្រួសារធម្មតា, យោងតាម២) តារាង៤-១

៣) សម្រាប់ប្រជារាស្ត្រ យោងតាម ២) តារាង១

តារាង៥. ចំនួន កំណើន និងអត្រាកំណើននៃសហគ្រាសបែងចែកតាមរាជធានី ខេត្ត ឆ្នាំ២០១១ និង ២០១៤

| លរ | រាជធានី ខេត្ត | ចំនួនសហគ្រាសឆ្នាំ ២០១៤ ១) (សហគ្រាស) | ចំនួនសហគ្រាសឆ្នាំ ២០១១ ២) (សហគ្រាស) | កំណើនក្នុងឆ្នាំ ២០១១-២០១៤ (សហគ្រាស) | លំដាប់ | អត្រាកំណើនក្នុងឆ្នាំ ២០១១-២០១៤ (%) | លំដាប់ |
|---|---|---|---|---|---|---|---|
| | **កម្ពុជា** | **514,278** | **463,363** | **50,915** | | **11.0** | |
| 01 | បន្ទាយមានជ័យ | 21,546 | 20,407 | 1,139 | 10 | 5.6 | 17 |
| 02 | បាត់ដំបង | 32,515 | 31,227 | 1,288 | 9 | 4.1 | 20 |
| 03 | កំពង់ចាម | 54,229 | 52,234 | 1,995 | 6 | 3.8 | 21 |
| 04 | កំពង់ឆ្នាំង | 22,827 | 18,525 | 4,302 | 3 | 23.2 | 3 |
| 05 | កំពង់ស្ពឺ | 22,258 | 21,765 | 493 | 18 | 2.3 | 23 |
| 06 | កំពង់ធំ | 21,006 | 20,633 | 373 | 21 | 1.8 | 24 |
| 07 | កំពត | 16,456 | 15,561 | 895 | 14 | 5.8 | 16 |
| 08 | កណ្តាល | 38,664 | 37,661 | 1,003 | 12 | 2.7 | 22 |
| 09 | កោះកុង | 5,452 | 4,685 | 767 | 16 | 16.4 | 8 |
| 10 | ក្រចេះ | 12,157 | 10,302 | 1,855 | 7 | 18.0 | 6 |
| 11 | មណ្ឌលគិរី | 2,594 | 2,195 | 399 | 20 | 18.2 | 5 |
| 12 | ភ្នំពេញ | 98,646 | 84,730 | 13,916 | 1 | 16.4 | 7 |
| 13 | ព្រះវិហារ | 6,136 | 5,028 | 1,108 | 11 | 22.0 | 4 |
| 14 | ព្រៃវែង | 29,521 | 27,738 | 1,783 | 8 | 6.4 | 15 |
| 15 | ពោធិ៍សាត់ | 14,270 | 10,790 | 3,480 | 4 | 32.3 | 2 |
| 16 | រតនគិរី | 6,095 | 5,271 | 824 | 15 | 15.6 | 9 |
| 17 | សៀមរាប | 37,617 | 27,923 | 9,694 | 2 | 34.7 | 1 |
| 18 | ព្រះសីហនុ | 10,789 | 9,870 | 919 | 13 | 9.3 | 13 |
| 19 | ស្ទឹងត្រែង | 4,608 | 4,412 | 196 | 23 | 4.4 | 19 |
| 20 | ស្វាយរៀង | 14,521 | 13,870 | 651 | 17 | 4.7 | 18 |
| 21 | តាកែវ | 32,778 | 29,813 | 2,965 | 5 | 9.9 | 11 |
| 22 | ឧត្តរមានជ័យ | 5,042 | 4,551 | 491 | 19 | 10.8 | 10 |
| 23 | កែប | 1,607 | 1,468 | 139 | 24 | 9.4 | 12 |
| 24 | ប៉ៃលិន | 2,945 | 2,704 | 241 | 22 | 8.9 | 14 |

១) សម្រាប់ចំនួនសហគ្រាស, យោងតាម១) តារាង១

២) សហគ្រាសតាមចញ្ចើមផ្លូវត្រូវបានដកចេញពីអង្កេតនេះ

# ផ្នែក៤

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១

# រាជរដ្ឋាភិបាលកម្ពុជា
Royal Government of Cambodia

# ក្រសួងផែនការ
Ministry of Planning

## អង្កេតចន្លោះជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៤
Cambodia Inter-censal Economic Survey 2014

## តារាងសំណួរ
Form

**សំងាត់បំផុត** STRICTLY CONFIDENTIAL

**ព័ត៌មាននេះប្រើប្រាស់សំរាប់តែគោលបំណងស្ថិតិប៉ុណ្ណោះ និងមិនប្រើប្រាស់សំរាប់ពន្ធដារទេ**

This is used only for the statistical purposes and not used for taxation.

ត្រឹមថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៤
As of 1st March 2014

### 1- ព័ត៌មានតំបន់ជំរឿន Area Information

| តំបន់ Area | ឈ្មោះ Name | កូដ Code | | |
|---|---|---|---|---|
| 1-1 រាជធានី /ខេត្ត Municipality/ Province | | | | |
| 1-2 ស្រុក/ខណ្ឌ /ក្រុង District/ Khan/ Krong | | | | |
| 1-3 ឃុំ /សង្កាត់ Commune/ Sangkat | | | | |
| 1-4 ភូមិ /មណ្ឌល Village/ Mondul | | | | |
| 1-5 មណ្ឌលជំរឿន Enumeration Area (EA) | | | | |

### 2-A ព័ត៌មានសហគ្រាស Establishment Information

| 2-1 លេខសហគ្រាសនៃសហគ្រាសដែលជ្រើសរើស Establishment number of the selected establishment | | | | | 2-2A ឈ្មោះសហគ្រាស ឬ អ្នកតំណាង Name of establishment or representative | 2-2B ប្រភេទអាជីវកម្ម Business type |
|---|---|---|---|---|---|---|
| ស្រង់ពី "បញ្ជីសហគ្រាស" from "Establishment List" | 2-1A ស្រង់ពី កូឡោនទី៦ from column 6 | | | | | |
| | ស្រង់ពី កូឡោនទី៧ from column 7 | | | | | |

| 2-3 អាស័យដ្ឋានសហគ្រាស Address of establishment | 2-3A ផ្លូវឈ្មោះ/លេខ Street Name/No. | 2-3B អគារលេខ ជាន់ទី បន្ទប់លេខ ។ល។ Building No., Floor No., Room No., etc. |
|---|---|---|
| | 2-3C ឈ្មោះផ្សារ ឬគ្រួសារនៅជិតជាងគេបំផុត Name of market, Name of nearest household etc. | |

| 2-4 ព័ត៌មានទំនាក់ទំនង Information for contact | 2-4A ទូរស័ព្ទការិយាល័យ Office Tel. No. | 2-4B ឈ្មោះអ្នកទំនាក់ទំនង Name of contact person | 2-4C ទូរស័ព្ទអ្នកទំនាក់ទំនង Tel. No. of contact person |
|---|---|---|---|
| | | | |

### 2-B ស្ថានភាពការសម្ភាសន៍ Interviewing Situation

| បំពេញដោយមន្ត្រីសម្ភាសន៍ ឬ មន្ត្រីត្រួតពិនិត្យ Filled-in by Enumerator/Supervisor | | | | |
|---|---|---|---|---|
| កាលបរិច្ឆេទចុងក្រោយនៃការបំពេញតារាងសំណួរ Final date of Form Survey | | | | |
| 2-5 ប្រភេទលទ្ធផលជំរឿន Type of survey result គូសរង្វង់លេខកូដ Circle the code | 1- បំពេញចប់ពេញលេញ Finished | 2- បដិសេធ ទាំងស្រុង Complete refusal | 3-បដិសេធ ចំណុចសំខាន់ៗ Serious refusal | 4- បដិសេធចំណុចបន្ទាប់ បន្សំ Minor refusal |
| កាលបរិច្ឆេទប្រគល់ "បញ្ជីសហគ្រាសពិសេស" ទៅអោយជំនួយការ/មន្ត្រីប្រចាំតំបន់ Date of handing "Special Survey List" to RO/ARO | | | | |

| បំពេញដោយជំនួយការមន្ត្រីប្រចាំតំបន់ Filled-in by RO/ARO | |
|---|---|
| កាលបរិច្ឆេទបញ្ចប់នៃការបំពេញ តារាងសំណួរ Date of finishing Survey | |
| ឈ្មោះជំនួយការមន្ត្រីតំបន់: Name of RO/ARO:…………………..………… ហត្ថលេខា Signature………………………………… | |

**ឈ្មោះមន្ត្រីសម្ភាសន៍** Enumerator: …………………………………………

កាលបរិច្ឆេទ Date: ………….…… ហត្ថលេខា Signature………………..

**ពិនិត្យដោយមន្ត្រីត្រួតពិនិត្យឈ្មោះ** Checked by Supervisor: …....…….……….………

កាលបរិច្ឆេទ Date: …………… ហត្ថលេខា Signature……………….……..

| 3- លក្ខណៈសំគាល់នៃអ្នកតំណាង ឬម្ចាស់សហគ្រាស<br>Characteristics of Representative and Owner of Establishment | 3-1 ភេទអ្នកតំណាងសហគ្រាស<br>Sex of Representative | 1- ប្រុស Male | 2- ស្រី Female | ☐ |
|---|---|---|---|---|
| | 3-2 ភេទម្ចាស់សហគ្រាស<br>Sex of Owner | 1- ប្រុស Male | 2- ស្រី Female | ☐ |
| | 3-3 សញ្ជាតិម្ចាស់ សហគ្រាស<br>Nationality of Owner | 1- ខ្មែរ Cambodian<br>2- ចិន Chinese<br>3- វៀតណាម Vietnamese<br>4- កូរ៉េ Korean<br>5- ជប៉ុន Japanese<br>6- ថៃ Thai<br>7- ម៉ាឡេស៊ី Malaysian<br>8- តៃវ៉ាន់ Taiwanese | 9- ប្រទេសអាស៊ានផ្សេងៗ Other ASEAN Countries<br>10- ប្រទេសអឺរ៉ុប EU Countries<br>11- ប្រទេសអាស៊ីផ្សេងៗ Other Asian Countries<br>12- ប្រទេសអាស៊ីមជ្ឈិមបូព៌ា Middle East Countries<br>13- ប្រទេសអាមេរិក United State of America<br>14- ផ្សេងៗសូមបញ្ជាក់ Others<br>Specify nationality<br>………………………………. | ☐ |

**4- ការចុះបញ្ជីនៅភ្នាក់ងាររដ្ឋបាល និង ឈ្មោះក្រសួង ឬស្ថាប័នដែលផ្តល់អាជ្ញាប័ណ្ណឬការអនុញ្ញាតសម្រាប់ដំណើរការអាជីវកម្ម**

Registration at Administrative Agencies and Names of Ministries or Agencies regarding License or Approval for the Business Operation

| | | | |
|---|---|---|---|
| 4-1 ការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្ម<br>Registration at the Ministry of Commerce or Provincial Department of Commerce | 1- បានចុះបញ្ជី<br>Registered | 2- មិនបានចុះបញ្ជី<br>Not registered | ☐ |
| 4-2 ឈ្មោះក្រសួង ឬ ស្ថាប័នផ្សេងៗដែលផ្តល់អាជ្ញាប័ណ្ណ ឬ ការអនុញ្ញាតផ្លូវការសំរាប់ ដំណើរការ អាជីវកម្មនៃសហគ្រាសនេះ Names of Ministries or Agencies regarding official license or approval for the business operation of this establishment.<br>ករណីសហគ្រាសមិនទទួលបានអាជ្ញាប័ណ្ណ ឬ ការអនុញ្ញាតផ្លូវការសំរាប់ដំណើរ ការអាជីវកម្មទេសូមសរសេរពាក្យថា "គ្មាន" នៅបន្ទាត់ខាងស្តាំទី ១។ In case of no official license or no approval, write "None" in the right frame No.1 | 4-2A | | សំរាប់ វ.ជ.ស *NIS use only* ☐ |
| | 4-2B | | ☐ |
| | 4-2C | | ☐ |
| | 4-2D | | ☐ |

**5 - ភាពជាកម្មសិទ្ធិនៃ សហគ្រាស (មូលដ្ឋានច្បាប់)** Ownership of Establishment (Legal Status)

| | | |
|---|---|---|
| 1- ក្រុមហ៊ុនឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី)<br>Individual proprietor (with no registration) | 6- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត<br>Public limited company | 11- សាខាក្រុមហ៊ុនបរទេស<br>Branch of a foreign company |
| 2- ក្រុមហ៊ុនឯកកម្មសិទ្ធិ (បានចុះបញ្ជី)<br>Sole proprietor (with registration) | 7- បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស<br>Subsidiary of a foreign company | 12- សហគ្រាសចំរុះរដ្ឋ<br>State joint venture |
| 3- ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ<br>General partnership | 8- សហគ្រាសរដ្ឋ State-owned organization<br>(រួមទាំងស្វយ័ត including autonomy-owned organization) | 13- អង្គការក្រៅរដ្ឋាភិបាល NGO<br>(Non-Governmental Organization) |
| 4- ក្រុមហ៊ុនសហកម្មសិទ្ធិមានកំរិត<br>Limited partnership | 9- សហគ្រាសឯកបុគ្គលទទួលខុសត្រូវ មានកំរិត<br>Single member private limited company | 14-សហករណ៍<br>Cooperative |
| 5- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត<br>Private limited company | 10- ការិយាល័យតំណាងពាណិជ្ជកម្មក្រុម ហ៊ុនបរទេស<br>Commercial representative office of a foreign company | 15- សហគ្រាសផ្សេងៗ<br>Others |

☐

| 6- ម៉ោងធ្វើអាជីវកម្ម<br>Business Hours | 6-1 ម៉ោងបើកអាជីវកម្ម<br>Opening time | ☐ ម៉ោង o'clock | ☐ នាទី minutes | គូសរង្វង់ Circle either of<br>1- ព្រឹក AM 2- ល្ងាច PM |
|---|---|---|---|---|
| | 6-2 ម៉ោងបិទអាជីវកម្ម<br>Closing time | ☐ ម៉ោង o'clock | ☐ នាទី minutes | គូសរង្វង់ Circle either of<br>1- ព្រឹក AM 2- ល្ងាច PM |

**7- ឆ្នាំចាប់ផ្តើមអាជីវកម្ម** Year of Starting the Business — ឆ្នាំ YEAR ☐☐☐☐

7-1 កត់ត្រាខែដែលចាប់ផ្តើមដំណើរការអាជីវកម្ម (ខែ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១១ ១២)
Month of Starting the Business (Month: 1, 2, 3, 4, 5, 6, 7, 8, 9,10,11,12) — ☐☐ ខែ MONTH

## 8- ការកាន់កាប់ទីកន្លែង ប្រភេទ និងផ្ទៃក្រឡាទីកន្លែងអាជីវកម្ម (ម៉ែត្រការ៉េ: ម២) Tenure, Kind and Area (square meters: m$^2$) of Business Place

| | | | | |
|---|---|---|---|---|
| 8-1 ការកាន់កាប់ទីកន្លែងអាជីវកម្ម<br>Tenure of Business Place | 1- កម្មសិទ្ធផ្ទាល់ខ្លួន<br>Owned | 2- ជួល<br>Rented | 3- ផ្សេងៗ Others (Specify)<br>(បញ្ជាក់ ........................................) | ☐ |

| | | | | |
|---|---|---|---|---|
| 8-2 ប្រភេទទីកន្លែងអាជីវកម្ម<br>Kind of Business Place | 1-អាជីវកម្មតាមផ្ទះ (កន្លែងធ្វើ អាជីវកម្មនិងកន្លែងស្នាក់នៅគឺ នៅ កន្លែងតែមួយ) Home business (Business place and owner's residence are united into one) | 2- អាជីវកម្មតាមអគារពាណិជ្ជកម្ម (កន្លែងធ្វើអាជីវកម្មនិងកន្លែងស្នាក់នៅគឺផ្សេងគ្នា) Business in apartment building (Business place and owner's residence are separate.) | 3-អាជីវកម្មតាមផ្សារប្រពៃណី (រួមបញ្ចូលផ្សារនៅក្នុងអគារទាប) Business in traditional market (including market in low-rise building) | ☐ |
| | 4-អាជីវកម្មតាមផ្សារទំនើប (អគារខ្ពស់ៗដែលមាន សហគ្រាសប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ) Business in modern shopping mall (high-rise building where a number of establishments are operating) | 5-អាជីវកម្មដែលមានទីតាំងដាច់ដោយឡែកតែឯង ឬអគារមួយតែឯង។ ឧ. ដូចជា រោងចក្រ ធនាគារ មន្ទីរពេទ្យ សាលារៀន វត្ត។ល។ Business occupying exclusively one block or one building (Ex: Factory, Bank, Hospital, School, Pagoda etc.) | 6- ផ្សេងៗ<br>Others | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 8-3 ផ្ទៃក្រឡាទីកន្លែងអាជីវកម្ម (ម៉ែត្រការ៉េ: ម២)<br>Area of Business Place (square meters: m$^2$) | 1-<br>ក្រោម 5 ម២<br>Under 5m$^2$ | 2-<br>5ម២ –ក្រោម 10ម២<br>5m$^2$- under 10m$^2$ | 3-<br>10ម២ – ក្រោម30ម២<br>10m$^2$- under 30m$^2$ | 4-<br>30ម២ –ក្រោម 50ម២<br>30m$^2$- under 50m$^2$ | 5-<br>50ម២ –ក្រោម 100ម២<br>50m$^2$- under 100m$^2$ | 6-<br>100ម២ –ក្រោម 200ម២<br>100m$^2$- under 200m$^2$ | 7-<br>200ម២ – ក្រោម 500ម២<br>200m$^2$- under 500m$^2$ | 8-<br>500ម២ –ក្រោម 1000ម២<br>500m$^2$- under 1000m$^2$ | 9-<br>1000ម២ ឡើងទៅ<br>1000m$^2$ and over | ☐ |

## 9- ចំនួនអ្នកចូលរួមការងារជាក់ស្តែងក្នុងសហគ្រាស ១សប្តាហ៍មុន ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៤ Number of Persons Engaged Actually in this Establishment one week before 1st March 2014.

- ករណីចម្លើយក្នុងសំណួរទី ៦ ឆ្លើយថាជា "ទីស្នាក់ការកណ្តាល" (សំណួរទី១១) ចំនួនអ្នកចូលរួមការងារនៅក្នុងសហគ្រាសជាសាខាមិនត្រូវរាប់បញ្ចូលទេ
- In the case of "Head office" (Q11), all persons engaged in its branch office(s) are excluded.

| | អ្នកចូលរួមការងារ Persons engaged | | | | |
|---|---|---|---|---|---|
| | 1- សរុប Total<br>(1=2+3 ឬ or 1= 4+5) | សញ្ជាតិ Nationality | | ភេទ Sex | |
| | | 2- ខ្មែរ Cambodian | 3-ជនបរទេស Foreigner | 4- ប្រុស Male | 5- ស្រី Female |
| **9-A សរុបចំនួនអ្នកចូលរួមការងារ (សរុប ៩- A១ ដល់ ៩- A៥)**<br>**Total number of persons engaged** (Total of "9-A1 to 9-A5") | | | | | |
| 9-A1 អ្នកចូលរួមការងារជាម្ចាស់សហគ្រាស<br>Individual proprietors / Sole proprietors (Self-employed proprietors) | | | | | |
| 9-A2 អ្នកធ្វើការងារជាសមាជិកគ្រួសារដោយគ្មានប្រាក់ឈ្នួល<br>Unpaid family workers | | | | | |
| 9-A3 នាយកដែលធ្វើការទទួលប្រាក់ខែ(មិនរាប់បញ្ចូលនាយកដែលធ្វើការមិនយកប្រាក់ខែ)<br>Paid directors (excluding unpaid directors) | | | | | |
| 9-A4 បុគ្គលិកធ្វើការជាប្រចាំ(អ្នកដែលបន្តធ្វើការច្រើនជាងមួយខែ) Regular employees (those who are employed on a continuous basis with more than one month period) | | | | | |
| 9-A5 កម្មករ/បុគ្គលិកធ្វើការផ្សេងៗ "ក្រៅពីបុគ្គលិកធ្វើការជាប្រចាំ"<br>Other employees than "regular employees" | | | | | |
| 9-B អ្នកចូលរួមការងារដោយស្ម័គ្រចិត្ត (ព្រះសង្ឃ អាចារ្យ ដូនជី ។ល។) មិនរាប់បញ្ចូល ចៅអធិការវត្តដែលគ្រប់គ្រងទេ Voluntarily-engaged persons (monks, clergyman etc.) excluding chief or director who controls the organization. | | | | | |

## 10- ប្រភេទសកម្មភាពអាជីវកម្មចំបងដែលសហគ្រាសប្រតិបត្តិការ

**Kind of Main Business Activities which this Establishment Only is Engaged in.**

- សូមពណ៌នា តើសហគ្រាសនេះធ្វើអ្វី ឧ- ការលក់ទំនិញ (លក់ដុំ ឬ លក់រាយ) ការផលិតទំនិញ ឬការជួសជុល ឬក៏ការផ្តល់សេវាកម្ម។
- សូមពណ៌នាប្រភេទទំនិញ ឬសេវាកម្មទាំងនេះ
- ករណីចម្លើយក្នុងសំណួរទី១១ ឆ្លើយថាជា "ទីស្នាក់ការកណ្តាល" មិនត្រូវរាប់បញ្ចូលសកម្មភាពទាំងឡាយរបស់សាខាទេ.
- Describe all that is done in this establishment. For example, selling (to wholesalers or consumers), manufacturing or repairing goods, or providing services.
- Describe about these goods or services also.
- In the case of "Head office" (Q11), all activities of its branch office(s) are excluded.

**សំរាប់ វ.ជ.ស** *NIS use only* ☐

## 11- អង្គភាពទោល ទីស្នាក់ការកណ្តាល ឬ សាខា Single Unit, Head Office or Branch Office

| | | | | |
|---|---|---|---|---|
| 11- អង្គភាពទោល ទីស្នាក់ការកណ្តាល ឬ សាខា<br>Single Unit, Head Office or Branch Office | 1- អង្គភាពទោល Single unit | 2-ទីស្នាក់ការកណ្តាល Head office | 3- សាខា Branch office | ☐ |
| | 11-1 (**ករណីចម្លើយជាសាខា**) (In the case of "Branch office")<br>តើទីស្នាក់ការកណ្តាលស្ថិតនៅទីណា?<br>Where is the Head office located? | 1- នៅខេត្តតែមួយ In Same Province<br>2- នៅខេត្តផ្សេងគ្នា In Other Province (បញ្ជាក់ ....................)<br>3-នៅបរទេស In Foreign country (បញ្ជាក់ ........................) | | ☐ |

**ចំពោះសហគ្រាសជា "សាខា" ត្រូវបញ្ចប់ការសម្ភាសន៍ត្រឹមនេះ** End of Interview for "Branch Office"

**សំណួរខាងក្រោមពីទី១២–១៤ ទាក់ទងតែនឹងសហគ្រាស "ទីស្នាក់ការកណ្តាល"** Questions 12 to 14 below refer only to establishments of "Head office".

| | |
|---|---|
| 12- **ចំនួនសាខាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្នាក់ការកណ្តាលនេះ**<br>Number of Branch offices that establishment supervises | |

| | |
|---|---|
| 13- **ចំនួនអ្នកចូលរួមការងារសរុបជាប្រចាំរបស់សហគ្រាសនៅដំណាច់ខែធ្នូ ឆ្នាំ ២០១៣** Number of the entire regular employees at the end of December 2013<br>▸ **"ចំនួនបុគ្គលិកធ្វើការសរុបជាប្រចាំ"ទាំងអស់នេះ" គឺរាប់បញ្ចូលទាំងបុគ្គលិកធ្វើការនៅទីស្នាក់ការកណ្តាល និងសាខា (ទីស្នាក់ការកណ្តាល + សាខា)** ▸The "entire regular employees" include employees of both head office and branch office(s) (namely, "Head office +Branch office(s)") | |

| | | |
|---|---|---|
| 14- **ប្រភេទសកម្មភាពអាជីវកម្មចំបងរបស់សហគ្រាសទាំងមូល ដោយរាប់បញ្ចូលទាំងនៅទីស្នាក់ការកណ្តាល និងសាខា (ទីស្នាការកណ្តាល + សាខា)** Kind of business activities of the entire entity that include not only those of this head office but also those of branch office(s) (namely, "Head office + Branch office(s)") | | |
| 14-1 ប្រភេទសកម្មភាពអាជីវកម្មចំបងរបស់សហគ្រាស Kind of main business activity<br>▸ជ្រើសរើសយកសកម្មភាពអាជីវកម្មណាមួយដោយផ្អែកលើចំណូលពីការលក់ច្រើនជាងគេបំផុតឬចំនួនបុគ្គលិកធ្វើការងារច្រើនជាងគេបំផុត។ State the main business activity in terms of largest value added or largest manpower input | | **សំរាប់ វ.ជ.ស** *NIS use only* |
| 14-2 ប្រភេទសកម្មភាពអាជីវកម្មចំបងទី២ក្នុងករណីដែលសហគ្រាសនោះមានសកម្មភាព២ ឬច្រើន Kind of the second biggest business activity if this entity has two or more kinds of activities. | | |

**សំណួរខាងក្រោមពីទី ១៥ –២១ សំរាប់សួរចំពោះសហគ្រាសជា "១-អង្គភាពទោល" និង "២-ទីស្នាក់ការកណ្តាល" តែប៉ុណ្ណោះដែលមាននៅក្នុងសំណួរទី ១១**
Questions 15 to 21 are asked only to establishments of "Single unit" and "Head office"(Q11).

| | | | |
|---|---|---|---|
| 15- **តើសហគ្រាសនេះមានរក្សាទុកឯកសារ តារាងតុល្យការ និងរបាយការណ៍ ចំណូលចំណាយដែរឬទេ?** Does this establishment or this entity keep Balance Sheet or Income Statement? | 1- មាន Yes<br>រំលងទៅសំណួរទី ១៧<br>Go to Q17 | 2- ទេ No<br>សួរសំណួរទី១៦ តែប៉ុណ្ណោះ<br>Go to Q16 | |

**សំណួរទី ១៦ សំដៅទៅលើគ្រប់សហគ្រាសជា "១-អង្គភាពទោល" និង "២-ទីស្នាក់ការកណ្តាល" ទាំងអស់ដែលមានចម្លើយថា "ទេ" នៅក្នុងសំណួរទី ១៥ តែប៉ុណ្ណោះ**
Question 16 refers to establishments of "Single unit" and "Head office" whose response to Question 15 is "No".

16- **ចំណូលលក់ ចំណាយប្រតិបត្តិការ និងចំនួនថ្ងៃធ្វើការក្នុងខែ កុម្ភៈ ឆ្នាំ២០១៤ ។ ប្រសិនបើចំណូលលក់ និងចំណាយប្រតិបត្តិការក្នុងខែកុម្ភៈ ឆ្នាំ២០១៤ មិនច្បាស់លាស់ទេ ត្រូវបំពេញចំណូលលក់ និងចំណាយប្រតិបត្តិការក្នុង១ខែកន្លងមក។ ករណីសហគ្រាសជា "ទីស្នាក់ការកណ្តាល" ត្រូវកត់ត្រាចំណូលលក់និងចំណាយប្រតិបត្តិការទាំងមូល រួមទាំងសាខាផងដែរ ។**

Amounts of revenues/sales and of operating expenses, and number of working days in February 2014. If the amount for February 2014 is unclear, figures of past one month should be filled in. In the case of "Head office", total amount of revenues/sales and operating expenses including its branch office(s) should be filled in.

**ជ្រើសរើសមួយ** Select one
ជាប្រាក់រៀល:១ *[in Riel]* :1
ជាប្រាក់ដុល្លារ:២ *[in USD]* :2

| | | | |
|---|---|---|---|
| 16-1 | ចំណូលលក់សរុបក្នុង១ខែ នៅខែកុម្ភៈ ឆ្នាំ២០១៤ ឬ១ខែកន្លងមក។ ប្រសិនបើចំណូល១ខែមិនច្បាស់លាស់ ត្រូវកត់ត្រាចំណូលក្នុង១ថ្ងៃ<br>Total amount of revenues/sales of one month in February 2014 or past one month. If the amount of one month is unclear, that of per day should be filled in.<br>▸ រួមបញ្ចូលរាល់ចំណូលទទួលបានពីសកម្មភាពប្រតិបត្តិការអាជីវកម្មដូចជា លក់ទំនិញ ផ្តល់សេវាកម្ម ។ល។<br>▸Include all income gained from operating activities such as selling of goods, providing services, etc. | 1- (១ខែ Per month) | |
| | | 2- (១ថ្ងៃ Per day) | |
| 16-2 | ចំណាយសរុបក្នុង១ខែនៅខែកុម្ភៈ ឆ្នាំ២០១៤ ឬ១ខែកន្លងមក។ ប្រសិនបើចំណាយ១ខែមិនច្បាស់លាស់ត្រូវកត់ត្រាចំណាយក្នុង១ថ្ងៃ។<br>Total amount of expenses of one month in February 2014 or past one month. If the amount of one month is unclear, that of per day should be filled in.<br>▸ រួមបញ្ចូលរាល់ការទូទាត់ចំណាយសំរាប់សកម្មភាពប្រតិបត្តិការអាជីវកម្មដូចជា ទិញផលិតផលសំរាប់លក់ សំភារៈឬឧបករណ៍សំរាប់ផ្តល់សេវាកម្ម ថ្លៃជួលហាង ប្រាក់ខែ និងប្រាក់ឈ្នួលសម្រាប់អ្នកគ្រប់គ្រងនិងបុគ្គលិក ពន្ធដារ។ល។<br>▸ Include all expenses for operating activities such as purchase of products for sales and costs for providing services, rent for shops and salaries and wages for managers and workers, tax, etc. | 1- (១ខែ Per month) | |
| | | 2- (១ថ្ងៃ Per day) | |
| | 16-2-1 ក្នុងចំណោមចំណាយសរុបក្នុង១ខែខាងលើ កត់ត្រាចំណាយប្រាក់ខែ និងប្រាក់ឈ្នួលសម្រាប់អ្នកគ្រប់គ្រងនិងបុគ្គលិកសរុបក្នុងខែកុម្ភៈ ឆ្នាំ ២០១៤ ឬ១ខែកន្លងមក ។ ប្រសិនបើចំណាយប្រាក់ខែក្នុង១ខែមិនច្បាស់លាស់ ត្រូវកត់ត្រាចំណាយប្រាក់ខែ និងប្រាក់ឈ្នួលក្នុង១ថ្ងៃ ។ Out of the total amount of expenses of one month, total amount of salaries and wages for managers and workers of one month in February 2014 or past one month. If the amounts of one month is unclear, that per day should be filled in. | 1- (១ខែ Per month) | |
| | | 2- (១ថ្ងៃ Per day) | |
| | 16-2-2 ក្នុងចំណោមចំណាយសរុបក្នុង១ខែខាងលើ កត់ត្រាចំណាយអគ្គីសនី (ជាវតែប៉ុណ្ណោះ) ក្នុងខែកុម្ភៈ ឆ្នាំ ២០១៤ ឬ១ខែកន្លងមក Out of the total amount of expenses of one month, electricity cost (purchased only) of one month in February 2014 or past one month. | ១ខែ Per month | |
| 16-3 | ចំនួនថ្ងៃធ្វើការក្នុងខែកុម្ភៈ ឆ្នាំ ២០១៤<br>Number of working days in February 2014 | | ថ្ងៃ days |

ចំពោះសហគ្រាសដែលមិនមាន "តារាងតុល្យការ" ឬ "របាយការណ៍ចំណូលចំណាយ" ត្រូវបញ្ចប់ការសម្ភាសន៍ត្រឹមនេះ
▸**Questions to establishments with no "Balance Sheet" and "Income Statement" are over here.**

**សំណួរខាងក្រោមពីទី ១៧–២១ សំដៅទៅលើសហគ្រាសជា “១-អង្គភាពទោល” និង “២-ទីស្នាក់ការកណ្តាល” ដែលមានចម្លើយថា “មាន”នៅក្នុងសំណួរទី ១៥ តែប៉ុណ្ណោះ។** Questions 17 to 21 below refer only to establishments of “Single unit” and “Head office” whose response to Question 15 is “ Yes”.

ផ្នែកនីមួយៗនៃសំណួរទាំងនេះត្រូវបាន ដកស្រង់ចេញពី “តារាង តុល្យការណ៍” និង “របាយការណ៍ចំណូលចំណាយ” ហើយការបំពេញសំណួរនេះ គឺគ្រាន់តែថតចំលងឯកសារពី “ចំនួនទឹកប្រាក់បច្ចុប្បន្ន” ដែលសហគ្រាសបានរក្សាទុកតែប៉ុណ្ណោះ។ ប្រសិនបើអាច សូមភ្ជាប់ជាមួយនូវច្បាប់ថតចំលងផងដែរ។
Each category of these questions can be extracted from “Balance Sheet” and “Income Statement”, and filled in by just copying from “Current Amount” of these documents which the establishment keeps. Submit the photocopy if possible.

**ជ្រើសរើសមួយ** Select one
ជាប្រាក់រៀល:១ *[in Riel]* :1
ជាប្រាក់ដុល្លារ:២ *[in USD]* :2
☐

| | | | |
|---|---|---|---|
| **17- ចំនួនទ្រព្យសកម្មសរុបនៅដំណាច់ខែ ធ្នូ ឆ្នាំ ២០១៣ (សរុប ១៧.១ និង ១៧.២)** Total Amount of Assets at the end of December 2013 ( Sum of 17-1 and 17-2 ) | | A0 | |
| **17-1** ទ្រព្យសកម្មរយ:ពេលវែង Non-current Assets / Fixed Assets | | A1 | |
| **17-2** ទ្រព្យសកម្មរយ:ពេលខ្លី (មិនមែនសរុបពី១៧-២-១ដល់១៧-២-៤ទេ) Current Assets (This is not the sum of 17-2-1 to 17-2-4) | | A13 | |
| សន្និធិ (of which) Inventories | **17-2-1** សន្និធិ/ ស្តុកវត្ថុធាតុដើម និងសំភារ:ផ្គត់ផ្គង់ Stocks of raw materials and supplies | A14 | |
| | **17-2-2** សន្និធិ/ ស្តុកទំនិញ Stocks of goods | A15 | |
| | **17-2-3** សន្និធិ/ ស្តុកផលិតផលសំរេច Stocks of finished products | A16 | |
| | **17-2-4** សន្និធិ/ ស្តុកផលិតផលពាក់កណ្តាលសំរេច Products in progress | A17 | |

| | | |
|---|---|---|
| **18- មូលនិធិនៅដំណាច់ ខែ ធ្នូ ឆ្នាំ ២០១៣** Equity held at the end of December 2013 | A28 | |
| **18-1** មូលធន/ មូលធនភាគហ៊ុន (of which) Capital / Share capital | A29 | |

| | | |
|---|---|---|
| **19- បំណុលរយ:ពេលវែងនៅដំណាច់ ខែ ធ្នូ ឆ្នាំ ២០១៣** Non-current Liabilities at the end of December 2013 | A36 | |
| **19-1** បំណុលភាគីជាប់ទាក់ទិន (of which) Loan from related parties | A37 | |
| **19-2** បំណុលធនាគារ និងបំណុលភាគីមិនជាប់ទាក់ទិនផ្សេងៗ (of which) Loan from banks and other external parties | A38 | |

| | | |
|---|---|---|
| **20- បំណុលរយ:ពេលខ្លីនៅដំណាច់ ខែ ធ្នូ ឆ្នាំ ២០១៣** (មិនមែនសរុបពី ២០-១ ដល់ ២០-៤ ទេ) **Current Liabilities at the end of December 2013** (This is not the sum of 20-1 to 20-4) | A41 | |
| **20-1** សាច់ប្រាក់ដកពីធនាគារលើសប្រាក់បញ្ញើ(ឥណទានវិបារូប៍រ) (of which) Bank overdraft | A42 | |
| **20-2** ចំណែកចរន្តនៃបំណុលមានការប្រាក់ (of which) Short-term borrowing-current portion of interest bearing borrowing | A43 | |
| **20-3** គណនីត្រូវសងបុគ្គលជាប់ទាក់ទិន (ភាគីសម្ព័ន្ធញាត្តិ) (of which) Accounts payable to related parties | A44 | |
| **20-4** គណនីត្រូវសងផ្សេងៗ (of which) Other accounts payable | A45 | |

**21- របាយការណ៍ចំណូល និងចំណាយក្នុងឆ្នាំ២០១៣ តាម “មូលដ្ឋានប្រុពន្ធគណនេយ្យ” ដែលកត់ត្រាពីចំណូល និងចំណាយពាក់ព័ន្ធក្នុងរយ:ពេលដូចគ្នា ។**
Amount of Revenues and Expenses in one year of Year 2013 under “Accrual basis accounting”, which records revenues and related expenses in the same period.

**ជ្រើសរើសមួយ** Select one
ជាប្រាក់រៀល:១ *[in Riel]* :1
ជាប្រាក់ដុល្លារ:២ *[in USD]* :2
☐

| | | |
|---|---|---|
| **21-1 ចំណូលប្រតិបត្តិការ (សរុបពី ២១.១.១ ដល់ ២១.១.៣)** Operating Revenues (Sum of 21-1-1 to 21-1-3) | B0 | |
| **21-1-1** ការលក់ផលិតផល Sales of products | B1 | |
| **21-1-2** ការលក់ទំនិញ Sales of goods | B2 | |
| **21-1-3** ការផ្គត់ផ្គង់សេវា Supplies of services | B3 | |
| **21-2 សរុបថ្លៃដើមប្រតិបត្តិការ (សរុបពី ២១.២.១ ដល់ ២១.២.៣)** Total of Operating Costs (Sum of 21-2-1 to 21-2-3) | - | |
| **21-2-1** ថ្លៃដើមផលិតផលបានលក់របស់សហគ្រាសផលិតកម្ម Cost of products sold of production enterprises | B4 | |
| **21-2-2** ថ្លៃដើមទំនិញបានលក់របស់សហគ្រាសក្រៅពីផលិតកម្ម Cost of goods sold of non-production enterprises | B 5 | |
| **21-2-3** ថ្លៃដើមសេវាបានផ្គត់ផ្គង់ Cost of services supplied | B5.1 | |

**21- របាយការណ៍ចំណូល និងចំណាយក្នុងឆ្នាំ២០១៣ តាម "មូលដ្ឋានប្រព័ន្ធគណនេយ្យ" (ត)**
Amount of Revenues and Expenses in a Year 2013 under "Accrual basis accounting". (Continued)

| | | | | |
|---|---|---|---|---|
| **21-3** | **ចំណូលផ្សេងៗ (សរុបពី ២១.៣ .១ ដល់ ២១.៣ .១១)** | Other Revenues (Sum of 21-3-1 to 21-3-11) | B7 | |
| 21-3-1 | ឧបត្ថម្ភធន | Grants / subsidies | B8 | |
| 21-3-2 | ចំណូលពីភាគលាភបានទទួល ឬ ត្រូវទទួល | Dividends received or receivable | B9 | |
| 21-3-3 | ចំណូលពីការប្រាក់បានទទួល ឬ ត្រូវទទួល | Interests received or receivable | B10 | |
| 21-3-4 | ចំណូលពីសួយសារបានទទួល ឬ ត្រូវទទួល | Royalties received or receivable | B11 | |
| 21-3-5 | ចំណូលពីការជួលបានទទួល ឬ ត្រូវទទួល | Rental fees received or receivable | B12 | |
| 21-3-6 | ផលចំណេញពីការលក់ទ្រព្យសកម្ម រយៈពេលវែង | Gain/surplus on disposal of fixed assets (capital gain) | B13 | |
| 21-3-7 | ផលចំណេញពីការលក់មូលប័ត្រ ឬ សញ្ញាប័ណ្ណ | Gain on disposal of securities | B14 | |
| 21-3-8 | ភាគចំណេញពីប្រតិបត្តិការរួមគ្នា | Share of profit from joint venture | B15 | |
| 21-3-9 | ផលចំណេញពីការប្តូរប្រាក់សំរេចបាន | Gain on realized currency translation | B16 | |
| 21-3-10 | ផលចំណេញពីការប្តូរប្រាក់មិនទាន់សំរេចបាន | Gain on unrealized currency translation | B17 | |
| 21-3-11 | ចំណូលដទៃទៀតក្រៅពីខាងលើ | Other revenues | B18 | |
| **21-4** | **ចំណាយប្រតិបត្តិការ (សរុបពី ២១.៤.១ ដល់ ២១.៤.១៩)** | Operating Expenses (Sum of 21-4-1 to 21-4-19) | B19 | |
| 21-4-1 | ចំណាយបៀវត្ស និងប្រាក់ឈ្នួល | Salaries expenses | B20 | |
| 21-4-2 | ចំណាយប្រេង អគ្គីសនី ឧស្ម័ន និងទឹក | Fuel, gas, electricity and water expenses | B21 | |
| 21-4-2-1 | ចំណាយអគ្គីសនី (ជាវតែប៉ុណ្ណោះ) | Electricity expense (purchased only) | - | |
| 21-4-3 | ចំណាយធ្វើដំណើរ និងចំណាយស្នាក់នៅ | Travelling and accommodation expenses | B22 | |
| 21-4-4 | ចំណាយដឹកជញ្ជូន | Transportation expenses | B23 | |
| 21-4-5 | ចំណាយលើការជួល | Rental expenses | B24 | |
| 21-4-6 | ចំណាយលើការថែទាំ និងជួសជុល | Repair and maintenance expenses | B25 | |
| 21-4-7 | ចំណាយលើការកំសាន្តសប្បាយ | Entertainment expenses | B26 | |
| 21-4-8 | ចំណាយលើកំរៃជើងសារ ផ្សាយពាណិជ្ជកម្ម និងចំណាយការលក់ | Commission, advertising, and selling expenses | B27 | |
| 21-4-9 | ចំណាយបង់ពន្ធ និងអាករផ្សេងៗ | Other taxes expense | B28 | |
| 21-4-10 | ចំណាយលើអំណោយ | Donation expense | B29 | |
| 21-4-11 | ចំណាយលើសេវាគ្រប់គ្រង ពិគ្រោះយោបល់ បច្ចេកទេស និងសេវាប្រហាក់ប្រហែល | Management, consulting, technical, and other similar services expense. | B30 | |
| 21-4-12 | ចំណាយលើសួយសារ | Royalty expense | B31 | |
| 21-4-13 | ចំណាយលើបំណុលទារមិនបាន | Written-off bad debts expense | B32 | |
| 21-4-14 | ចំណាយរំលស់ | Amortization, depletion, and/or depreciation expense | B33 | |
| 21-4-15 | ការកើនឡើង ឬថយចុះសំវិធានធន | Increase/decrease in provisions | B34 | |
| 21-4-16 | ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង | Loss on disposal of fixed assets | B35 | |
| 21-4-17 | ខាតពីការប្តូរប្រាក់សំរេចបាន | Loss on realised currency translation | B36 | |
| 21-4-18 | ខាតពីការប្តូរប្រាក់មិនទាន់សំរេចបាន | Loss on unrealised currency translation | B37 | |
| 21-4-19 | ចំណាយផ្សេងៗ | Other expenses | B38 | |
| **21-5** | **ចំណាយការប្រាក់បង់អោយនិវាសនជន** | Interest expense paid to residents | B40 | |
| **21-6** | **ចំណាយការប្រាក់បង់អោយអនិវាសនជន** | Interest expense paid to non-residents | B41 | |
| **21-7** | **ពន្ធលើប្រាក់ចំណេញ** | Profit tax | B43 | |

**21- របាយការណ៍ចំណូល និងចំណាយក្នុងឆ្នាំ២០១៣ តាម "មូលដ្ឋានប្រព័ន្ធគណនេយ្យ" (ត)**
Amount of Revenues and Expenses in a Year 2013 under "Accrual basis accounting". (Continued)

21-8 **ថ្លៃដើមផលិតផលបានលក់ (សហគ្រាសផលិតកម្ម)** Costs of Products Sold (Production Enterprise)

| | | |
|---|---|---|
| **21-8-1** ចំណាយថ្លៃដើមវត្ថុធាតុដើម និងសម្ភារៈផ្គត់ផ្គង់ដែលបានប្រើប្រាស់ Expenses on raw materials and supplies used | C6 | |
| **21-8-2** ចំណាយផ្សេងៗក្នុងផលិតកម្ម Other Production Costs | C7 | |
| **21-8-3** ប្រាក់បៀវត្សអ្នកគ្រប់គ្រង និងកម្មករសម្រាប់ការផលិត Salaries for managers and workers in the production | C8 | |
| **21-8-4** រំលស់ទ្រព្យសកម្មអរូបីរយៈពេលវែងដូចជាមូលនិធិពាណិជ្ជកម្ម Amortization of intangible assets such as goodwill, license… | C9 | |
| **21-8-5** ចំណាយប្រេងឥន្ធនៈ និងថាមពល Fuel, water and power | C10 | |
| **21-8-5-1** ចំណាយអគ្គីសនី (ជាវតែប៉ុណ្ណោះ) Electricity expense (purchased only) | - | |
| **21-8-6** ការវេចខ្ចប់ Packaging | C11 | |
| **21-8-7** រំលស់រោងចក្រ គ្រឿងម៉ាស៊ីន និងបរិក្ខាផ្សេងៗទៀតក្នុងផលិតកម្ម Depreciation of plants and equipment | C12 | |
| **21-8-8** សេវាម៉ៅការបន្ត និងសេវាផលិតដោយសហគ្រាសដទៃ Sub-contract and production services costs by other enterprises | C13 | |
| **21-8-9** ចំណាយផ្សេងៗក្នុងផលិតកម្ម Other manufacturing costs | C14 | |
| **21-8-10** ការងារកំពុងដំណើរការ ឬស្តុកកំពុងផលិតនៅដើមគ្រា Work in progress or stock in progress at the beginning of the period | C15 | |
| **21-8-11** ដក: ការងារកំពុងដំណើរការ ឬស្តុកកំពុងផលិតនៅចុងគ្រា Less: Work in progress or stock in progress at the end of the period | C16 | |
| **21-8-12** សរុបចំណាយថ្លៃដើមផលិតកម្ម Total Production Costs | C17 | |
| **21-8-13** ស្តុកផលិតផលសម្រេចនៅដើមគ្រា Stock of finished products at the beginning of the period | C18 | |
| **21-8-14** ដក: ស្តុកផលិតផលសម្រេចនៅចុងគ្រា Less: Stock of finished products at the end of the period | C19 | |

| | |
|---|---|
| ពិនិត្យដោយមន្ត្រីសម្ភាសន៍ Checked by enumerator | ត្រឹមត្រូវ Correct ប្រសិនបើត្រឹមត្រូវសូមគូសរង្វង់លើពាក្យ (ត្រឹមត្រូវ) If it is "correct", circle this |

បានឃើញ និងបញ្ជាក់ថាព័ត៌មានដែលបានបំពេញពិតជាត្រឹមត្រូវ
I certify that the information filled in the Form is accurate

ធ្វើនៅ........................ថ្ងៃទី........................ខែ......................ឆ្នាំ ២០១៤
Issued at ……………..Date…………………….........
ហត្ថលេខា/ត្រាម្ចាស់សហគ្រាស ឬអ្នកតំណាងសហគ្រាស
Signature/stamp of Establishment Owner/Manager

……………………..……………………………......

## កំណត់ហេតុ MEMORANDUM

| កាលបរិច្ឆេតជួសម្កាស<br>Date of Visit | លទ្ធផល/កំណត់សំគាល់ Results/Remarks |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

**កំណត់សំគាល់** Remarks:

ឧបសម្ព័ន្ធ២

**សំងាត់បំផុត**

# រាជរដ្ឋាភិបាលកម្ពុជា

## អង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤

## តារាងបញ្ជីសហគ្រាស

## តាមភូមិ ឬ មណ្ឌលអង្កេត

(ត្រឹមថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៤)

លេខទំព័រ ..................
ចំនួនទំព័រសរុប............

| | រាជធានី ខេត្ត | | ស្រុក ខណ្ឌ ក្រុង | | ឃុំ សង្កាត់ | | ភូមិ | | កូដមណ្ឌលអង្កេត | | | ចំនួនសហគ្រាស | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះ | | | | | | | | | | | | សរុប | ត្រូវសម្ភាសន៍ | មានបន្តពី ២០១១ | ថ្មី | រកមិនឃើញ |
| កូដ | | | | | | | | | | | | | | | | |

| លរ សហគ្រាស | ឈ្មោះសហគ្រាស (ឈ្មោះ បានចុះបញ្ជី ប្រសិនបើគ្មាន បានចុះបញ្ជីទេ ដាក់ឈ្មោះម្ចាស់សហគ្រាស) | ប្រភេទអាជីវកម្ម បញ្ជាក់សកម្មភាពចំបង របស់សហគ្រាស(ឧ-ដូចជាភោជនីយដ្ឋាន ហាងលក់ទំនិញ វត្តអារាម សាលារៀន ....។ល។) | អាស័យដ្ឋានសហគ្រាស (ឈ្មោះផ្លូវ... អាគារ... ជាន់ទី.... លេខតូប... ប្រសិនបើមិនច្បាស់ទេ សូមដាក់អាស័យដ្ឋាននៅជិតនោះ ។ល។ ) | ចំនួនអ្នកចូលរួមការងារ | សហគ្រាសលេខ (ពីតារាងបញ្ជីសហគ្រាសបឋម ប្រសិនបើមានសហគ្រាសដូចគ្នា) | លរ សហគ្រាស(ថ្មី) លើកលែងសហគ្រាសមានអ្នកចូលរួម ៥០នាក់ឡើង (គូសរង្វង់លើសហគ្រាសជ្រើសរើស) | ប្រភេទលទ្ធផលអង្កេត ១-ចប់ពេញលេញ (បដិសេធ) ២-ទាំងស្រុង ៣-ចំណុចសំខាន់ៗ ៤-ចំណុចបន្ទាប់បន្សំ |
|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**មន្ត្រីសម្ភាសន៍**
កាលបរិច្ឆេទ.........................ឈ្មោះ................................ ហត្ថលេខា.......................

លេខ២ខ្ទង់ចុងក្រោយនៃក្រដាស់ប្រាស់..........

**ពិនិត្យដោយមន្ត្រីត្រួតពិនិត្យ**
កាលបរិច្ឆេទ.........................ឈ្មោះ.......................... ហត្ថលេខា.......................

# ច្បាប់
# ស្ដីពីស្ថិតិ

នស/រកម/០៥០៥/០១៥

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់ យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ

បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋា-ភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីស្ថិតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

៣

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់ស្ថិតិនេះ គ្រប់គ្រងការងារទាំងឡាយ ដែលទាក់ទងដល់ការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យស្ថិតិ ហើយមានវិសាលភាពគ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ពាក្យបច្ចេកទេសទាំងឡាយនៃច្បាប់នេះមានន័យដូចខាងក្រោម :

ក-ស្ថិតិ គឺជាទិន្នន័យដែលបានមកដោយការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយលទ្ធផលនៃចម្លើយតាមការប្រមូលស្ថិតិ ឬពីប្រភពទិន្ន-ន័យរដ្ឋបាល ។

ខ-ប្រព័ន្ធស្ថិតិជាតិ គឺជាសមាហរណកម្មនៃទិន្នន័យស្ថិតិថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិរួមបញ្ចូលទាំងទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ និងអង្គភាពស្ថិតិក្នុងក្រសួងនិងស្ថាប័នរាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ។

គ-ស្ថិតិគ្រឹះ គឺជាស្ថិតិផ្លូវការស្តីពីសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រ ដែលជាស្ថិតិមានចរិតទាក់ទងនឹងផ្នែកជាច្រើនកម្រិតជាតិ មូលដ្ឋាន ដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ កម្មវិធី និងការវាយតម្លៃក៏ដូចជាការប្រើប្រាស់ដ៏ទូលាយរបស់សហគមន៍ជាតិ និងអន្តរជាតិ ។

ឃ-ស្ថិតិតាមវិស័យ គឺជាស្ថិតិដែលប្រមូលដោយបណ្តាក្រសួង ស្ថាប័នរាជរដ្ឋា-ភិបាលសម្រាប់តម្រូវការផ្ទៃក្នុងផ្ទាល់ខ្លួន និងគោលដៅធ្វើរបាយការណ៍ ។

ង-ជំរឿន គឺជាការប្រមូលស្ថិតិពីបុគ្គល គ្រួសារ សហគ្រាស ឬ អង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពទាំងអស់ត្រូវបានធ្វើសម្ភាសន៍ ។

ច-អង្កេត គឺជាការប្រមូលទិន្នន័យតាមបែបវិទ្យាសាស្ត្រពីបុគ្គល គ្រួសារ សហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពជ្រើសរើសគំរូតែប៉ុណ្ណោះ ត្រូវបានសម្ភាសន៍ ។

ឆ-មន្ត្រីស្ថិតិ គឺជាមន្ត្រីរាជរដ្ឋាភិបាល ដែលមានសិទ្ធិអំណាចក្នុងការធ្វើសកម្មភាពស្ថិតិផ្លូវការ ។

ជ-អ្នកឆ្លើយ គឺជាបុគ្គល គ្រួសារ ក្រុមហ៊ុន សហគ្រាស ស្ថាប័ន រាជរដ្ឋាភិបាល ឬក្រៅរដ្ឋាភិបាល ឬអង្គការផ្សេងទៀត ដែលត្រូវបានជ្រើសរើសក្នុងការជំរឿន ឬអង្កេត ។

ឈ-ទិន្នន័យ គឺជាព័ត៌មានដែលមានរូបភាពជាតួលេខ ។

ញ-"ស្ថិតិផ្លូវការដែលបានចាត់តាំង" គឺជាស្ថិតិដែលបានផលិតដោយក្រសួង ស្ថាប័នដែលកំណត់ដោយរាជរដ្ឋាភិបាល ដើម្បីបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយក្នុងការរៀបចំវាយតម្លៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឆ្លើយតបទៅនឹងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេស ក៏ដូចជាបម្រើសេចក្តីត្រូវការព័ត៌មានរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ ។

## ជំពូកទី ២

## គោលការណ៍ និងទិសដៅ

**មាត្រា ៣.-**

ការអភិវឌ្ឍន៍ស្ថិតិ ត្រូវឈរលើមូលដ្ឋាននៃគោលការណ៍ : ភាពត្រឹមត្រូវ ភាពឯករាជ្យ ភាពសព្វានុម័ត ភាពគួរទុកចិត្តបាន ភាពសំខាន់ និងភាពទាន់ពេលវេលា ។

**មាត្រា ៤.-**

សកម្មភាពស្ថិតិ ត្រូវដឹកនាំទៅតាមទិសដៅដូចតទៅ :

ក-គាំទ្រសេចក្តីត្រូវការទិន្នន័យស្ថិតិរបស់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំវាយតម្លៃគោលនយោបាយ និងកម្មវិធី សេដ្ឋកិច្ច សង្គមកិច្ច ដែលផ្តោតលើកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងសុខុមាលភាពរបស់ប្រជាជាតិ ក៏ដូចជាសេចក្តីត្រូវ

ការសម្រាប់អ្នកធ្វើសេចក្តីសម្រេច និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ

ខ-សម្រួលកិច្ចអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិឱ្យមានសមត្ថភាព និងប្រសិទ្ធភាព

គ-បង្កើនការយល់ដឹងជាសាធារណៈ នូវសារៈសំខាន់អំពីមុខងារ និងតួនាទី របស់ស្ថិតិនៅក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិ

ឃ-លើកទឹកចិត្តដល់កិច្ចអភិវឌ្ឍន៍ វិធីសាស្ត្រ និងបច្ចេកវិជ្ជានៅក្នុងសកម្មភាពស្ថិតិ ។

## ជំពូកទី ៣
## ការប្រមូលទិន្នន័យស្ថិតិ

**មាត្រា ៥.–**

ទិន្នន័យស្ថិតិត្រូវបានប្រមូលតាមរយៈ :

ក-ការធ្វើជំរឿន

ខ-ការធ្វើអង្កេត

គ-ការទទួលបានទិន្នន័យរដ្ឋបាលពីប្រភពរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ។

**មាត្រា ៦.–**

ជំរឿនដូចមានចែងក្នុងមាត្រា ៥ កថាខណ្ឌ ក នៃច្បាប់នេះ ត្រូវដំណើរការយ៉ាងតិចមួយដងក្នុងរយៈពេល១០ឆ្នាំ ។

ជំរឿនមាន ៣ ប្រភេទ :

ក-ជំរឿនប្រជារាស្ត្រ

ខ-ជំរឿនកសិកម្ម

គ-ជំរឿនសហគ្រាស ។

ជំរឿនទាំងនេះ ត្រូវអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៧.–**

រាជរដ្ឋាភិបាលត្រូវកំណត់កាលបរិច្ឆេទ សម្រាប់ដំណើរការជំរឿនទាំងបីដោយអនុក្រឹត្យ ក្នុងរយៈពេល ១០ឆ្នាំម្តង ។ កាលបរិច្ឆេទនេះ អាចធ្វើការផ្លាស់ប្តូរបានក្នុងករណីចាំបាច់ ។

**មាត្រា ៨.–**

អង្កេតចន្លោះជំរឿនទាំងឡាយ អាចត្រូវបានដំណើរការក្នុងចន្លោះជំរឿនពីរសម្រាប់ធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំនូវទិន្នន័យជំរឿនគោល ដើម្បីចងក្រងស្ថិតិសេដ្ឋកិច្ច និងសង្គមកិច្ចត្រឹមត្រូវ គួរទុកចិត្តបាន ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងអ្នកប្រើប្រាស់នានា ។

**មាត្រា ៩.–**

អង្កេតដូចមានចែងក្នុងមាត្រា ៥ កថាខណ្ឌ ខ នៃច្បាប់នេះ ត្រូវបានដំណើរការតាមពេលកំណត់ដើម្បីផលិតស្ថិតិជាតិជាគ្រឹះដ៏ត្រឹមត្រូវគួរទុកចិត្តបាននិងជាពិសេសដើម្បីបម្រើសេចក្តីត្រូវការទិន្នន័យស្ថិតិបន្ទាន់របស់រាជរដ្ឋាភិបាល ។ ក្នុងគោលបំណងធ្វើអង្កេតសេដ្ឋកិច្ចវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបង្កើតបញ្ជីពាណិជ្ជកម្ម ឬក្របខ័ណ្ឌសរុប ដើម្បីរក្សាទុក និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ។

**មាត្រា ១០.–**

ស្ថិតិដែលផលិតចេញពីប្រភពទិន្នន័យរដ្ឋបាលដូចមានចែងក្នុងមាត្រា ៥ កថាខណ្ឌ គ នៃច្បាប់នេះ ត្រូវចងក្រងដោយប្រើប្រាស់ទិន្នន័យកត់ត្រាក្នុងឯកសារ តារាង និងកំណត់ត្រាផ្សេងៗដែលមានប្រភពពីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។ ក្នុងគោលដៅចងក្រងស្ថិតិពីប្រភពទិន្នន័យរដ្ឋបាល វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវធ្វើសៀវភៅរាយឈ្មោះ និងទីតាំងរបស់ប្រភពទិន្នន័យស្ថិតិ និងរដ្ឋបាលដែលត្រូវថែរក្សា និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ។

**មាត្រា ១១.–**

ក្នុងក្របខ័ណ្ឌនៃច្បាប់នេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការមានភារកិច្ចទទួលខុសត្រូវក្នុងការ ៖

- ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យគ្រឹះតាមការធ្វើជំរឿន អង្កេត និងប្រើប្រាស់ប្រភពទិន្នន័យរដ្ឋបាល

- ចងក្រងគណនេយ្យជាតិកម្ពុជា និងសន្ទស្សន៍ថ្លៃក៏ដូចជាសូចនាករសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រ ។

**មាត្រា ១២.-**

បណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ត្រូវប្រមូលទិន្នន័យតាមផ្នែកដោយខ្លួនឯង ឬ ដោយសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការតាម :

- ការធ្វើអង្កេត
- ការប្រមូលទិន្នន័យស្ថិតិពីការកត់ត្រារដ្ឋបាល ។

## ជំពូកទី ៤

## ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

**មាត្រា ១៣.-**

វិទ្យាស្ថានជាតិស្ថិតិ ស្ថិតក្រោមឱវាទក្រសួងផែនការមានភារកិច្ចកសាងគោលនយោបាយស្ថិតិផ្លូវការក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័ន ។ ដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៤.-**

ក្នុងភារកិច្ចនេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវ :

ក-ធ្វើការសម្របសម្រួលក្នុងសកម្មភាពនៃកិច្ចអភិវឌ្ឍន៍ស្ថិតិរួមនិងការបណ្តុះបណ្តាលជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងផ្នែកឯកជន ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

ខ-ធ្វើកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពស្ថិតិជាមួយអង្គការ អន្តរជាតិ អង្គភាពស្ថិតិជាតិនៃប្រទេសនានា និងផ្នែកឯកជននានាទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន

គ-កំណត់ស្តង់ដារស្ថិតិជាតិ ដែលទាក់ទងនឹងចំណាត់ថ្នាក់ ទស្សនទាន និយមន័យ

និងអង្គពិនិត្យពិចារណាស្ថិតិ ដើម្បីចៀសវាងការភ័ន្តច្រឡំពីសំណាក់អ្នកប្រើប្រាស់ទិន្នន័យ និង ការជាន់គ្នាក្នុងការផលិតទិន្នន័យស្ថិតិផ្លូវការ ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាស្ថិតិ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រឹក្សាជូនក្រសួងផែនការក្នុងការជំរុញ កិច្ចអភិវឌ្ឍន៍ប្រព័ន្ធ ស្ថិតិជាតិ ។

សមាសភាព តួនាទី និងភារកិច្ច របស់ក្រុមប្រឹក្សាស្ថិតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៦.-**

គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានបង្កើតឡើងដើម្បីជួយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក្នុងការសម្របសម្រួលផ្នែកបច្ចេកទេសស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល ។

សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវកំណត់ ដោយអនុក្រឹត្យ ។

## ជំពូកទី ៥

## រចនាសម្ព័ន្ធ

**មាត្រា ១៧.-**

វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នស្ថិតិជាតិផ្លូវការ ជាអគ្គនាយកដ្ឋានចំណុះក្រសួងផែនការ ហើយមាននាយកដ្ឋានមួយចំនួនទទួលខុសត្រូវសកម្មភាពស្ថិតិ ដោយឡែកៗ ។

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការមានរចនាសម្ព័ន្ធនៅតាមខេត្ត ក្រុង ស្រុក ខ័ណ្ឌនិង ឃុំ សង្កាត់ ។

**មាត្រា ១៨.-**

បណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ដែលត្រូវផលិតស្ថិតិផ្លូវការក្នុងច្បាប់នេះ ត្រូវ បង្កើតអង្គភាពស្ថិតិនៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួន សម្រាប់បម្រើឱ្យគោលដៅស្ថិតិ ហើយត្រូវផ្ញើ ទិន្នន័យស្ថិតិដែលផលិតបានមកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ។

## ជំពូកទី ៦
## ការបោះពុម្ព និងផ្សព្វផ្សាយ

**មាត្រា ១៩.-**

ដើម្បីបម្រើនូវសំណូមពរស្ថិតិរបស់អ្នកប្រើប្រាស់ :

ក-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក៏ដូចជាអង្គភាពស្ថិតិនៃក្រសួង ស្ថាប័នផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ត្រូវបោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិ ដែលបានផលិតជូនដល់អ្នកប្រើប្រាស់ទាំងអស់

ខ-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវបោះពុម្ពព្រឹត្តិបត្រ ស្ថិតិប្រចាំឆ្នាំដែលគ្របដណ្តប់ទិដ្ឋភាពសំខាន់ៗនៃល័ក្ខខ័ណ្ឌសេដ្ឋកិច្ច សង្គមកិច្ច របស់ប្រទេស ។

**មាត្រា ២០.-**

រាល់ទិន្នន័យស្ថិតិដែលប្រកាសផ្សាយ ដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំងដោយរាជរដ្ឋាភិបាល ។

## ជំពូកទី ៧
## សិទ្ធិនិងភារកិច្ច

**មាត្រា ២១.-**

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអង្គភាពស្ថិតិតាមបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវបានអនុញ្ញាតឱ្យដំណើរការសកម្មភាពស្ថិតិនានា ដើម្បីទទួលបាននូវព័ត៌មានស្ថិតិពីអ្នកឆ្លើយសម្រាប់ផលិតស្ថិតិផ្លូវការដោយយោងទៅតាមមាត្រា ១១ និង ១២ នៃច្បាប់នេះ ។

**មាត្រា ២២.-**

មន្ត្រីរាជការ បុគ្គលិក ធ្វើការនៅក្នុងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាមន្ត្រីស្ថិតិ ដែលបានចាត់តាំងដោយអង្គការទាំង

នោះ នៅពេលបម្រើការងារ ឬបំពេញភារកិច្ចក្រោមច្បាប់នេះ ត្រូវធានារក្សាការសម្ងាត់នូវរាល់ព័ត៌មានបុគ្គលទាំងឡាយដែលបានមកពីអ្នកឆ្លើយ លើកលែងតែក្នុងករណីពិសេសដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងផែនការ ។ ព័ត៌មានដែលប្រមូលបានក្រោមច្បាប់នេះ ត្រូវយកមកប្រើប្រាស់តែក្នុងគោលដៅស្ថិតិប៉ុណ្ណោះ ។

**មាត្រា ២៣.-**

មន្ត្រីស្ថិតិនៃក្រសួងផែនការ ឬក្រសួង ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាល មានសិទ្ធិចេញចូលក្នុងបរិវេណលំនៅដ្ឋានដោយមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ឬអ្នកស្នាក់នៅ សម្រាប់គោលដៅប្រមូលទិន្នន័យស្ថិតិ :

ក-លំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅ រួមមានផ្ទះសំបែង ឬផ្នែកនៃទីបរិវេណផ្សេងទៀត ដែលមានមនុស្សស្នាក់នៅជាប់ដោយឡែក ។

ខ-ទីកន្លែងផ្សេងៗទៀត ។

**មាត្រា ២៤.-**

មន្ត្រីស្ថិតិដែលបានចាត់តាំងដោយក្រសួងផែនការ និងបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវបង្ហាញលិខិតបញ្ជាបេសកកម្មរបស់ខ្លួន និងអត្តសញ្ញាណប័ណ្ណផ្លូវការជូនដល់អ្នកឆ្លើយ ហើយត្រូវប្រកាន់អាកប្បកិរិយាសុភាពរាបសា និងវិជ្ជាជីវៈក្នុងការសាកសួរព័ត៌មានឱ្យបានសមស្របទៅតាមទំនៀមទម្លាប់មូលដ្ឋាន និងសណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា ២៥.-**

អ្នកឆ្លើយទាំងឡាយ ត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ គ្រប់គ្រាន់និងទាន់ពេលវេលា ជូនមន្ត្រីស្ថិតិដែលបានចាត់តាំងដោយក្រសួងផែនការ និងបណ្តាក្រសួងស្ថាប័នរាជរដ្ឋាភិបាល ។

## ជំពូកទី ៨

## ទោសប្បញ្ញត្តិ

**មាត្រា ២៦.-**

មន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលបានចាត់តាំងទាំងអស់នៃក្រសួងផែនការ និងបណ្តាក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ២២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោស

ដាក់ពន្ធនាគារ ពី ១ខែ(មួយខែ) ដល់ ៦ ខែ (ប្រាំមួយខែ) និង/ ឬ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០ រៀល(ហាសិបពាន់រៀល)ដល់២០០.០០០រៀល(ពីររយពាន់រៀល) ។

**មាត្រា ២៧.-**

មន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលបានចាត់តាំងទាំងអស់នៃក្រសួងផែនការ និងបណ្តាក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ២៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ថ្ងៃ(មួយថ្ងៃ) ដល់៦ថ្ងៃ(ប្រាំមួយថ្ងៃ) និង/ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០ រៀល(ដប់ពាន់រៀល) ដល់ ៥០.០០០ រៀល(ហាសិបពាន់រៀល) ។

**មាត្រា ២៨.-**

បណ្តាអ្នកឆ្លើយណា ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ២៥នៃច្បាប់នេះ ដោយចេតនាត្រូវផ្តន្ទាទោសដូចតទៅ :

ក-បុគ្គល ឬ មេគ្រួសារត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០រៀល (ដប់ពាន់រៀល) ដល់ ៥០.០០០រៀល (ហាសិបពាន់រៀល) ។

ខ-នាយក ឬ និយោជិតទទួលខុសត្រូវក្នុងក្រុមហ៊ុន ឬ សហគ្រាស ឬ អង្គការផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ (មួយខែ)ដល់ ៦ ខែ (ប្រាំមួយខែ) និង/ ឬ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០រៀល (មួយលានរៀល) ដល់ ៤.០០០.០០០ រៀល (បួនលានរៀល) ។

**មាត្រា ២៩.-**

បុគ្គលណាដែលទប់ស្កាត់ដោយចេតនា ឬ ហាមឃាត់ដោយគ្មានមូលហេតុផ្លូវច្បាប់មិនឱ្យសកម្មភាពស្ថិតិដំណើរការដោយវិទ្យាស្ថានជាតិស្ថិតិ ឬ បណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល តាមច្បាប់នេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ថ្ងៃ(ប្រាំពីរថ្ងៃ)ដល់ ១ ខែ (មួយខែ) និង/ ឬ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៦០០.០០០រៀល (ប្រាំមួយរយពាន់រៀល) ដល់ ១.៥០០.០០០ រៀល (១លានប្រាំសែនរៀល) ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៣០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥

នស/រកម.០៩០៥.២២៧

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

## ភាពគ្របដណ្តប់ នៃជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១១

| (ផ្នែកនៃចំណាត់ថ្នាក់វិស័យ ស្តង់ដារអន្តរជាតិ Rev/4. ១) | | ប្រភេទសហគ្រាស | | |
|---|---|---|---|---|
| | | ទីតាំង ជាប់លាប់ | ទីតាំងជាប់លាប់ ប៉ុន្តែអាចរុះរើបាន | ទីតាំង ចល័ត |
| A | កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | | | |
| B | សកម្មភាពអាជីវកម្មរ៉ែ និងថ្ម | | | |
| C | សកម្មភាពផលិតកម្ម | | | |
| D | ការផ្គត់ផ្គង់អគ្គីសនី ឧស្ម័ន ចំហាយ និង ខ្យល់ត្រជាក់ | | | |
| E | ការផ្គត់ផ្គង់ទឹក ការងារគ្រប់គ្រងទឹកស្អុយ កាកសំណល់ និងការកែច្នៃកាកសំណល់ | | | |
| F | សំណង់ | | | |
| G | ការលក់ដុំ និងលក់រាយ ការជួសជុលយានយន្ត និងទោចក្រយានយន្ត | | | |
| H | ការដឹកជញ្ជូន និងស្តុកទុក | | | |
| I | សកម្មភាពខាងការស្នាក់នៅ និងសកម្មភាពសេវាផ្នែកចំណីអាហារ | | | |
| J | ផ្នែកព័ត៌មានវិទ្យា និងទំនាក់ទំនងទូរគមនាគមន៍ | | | |
| K | សកម្មភាពហិរញ្ញវត្ថុ និងការធានារ៉ាប់រង | | | |
| L | សកម្មភាពអចលនទ្រព្យ | | | |
| M | សកម្មភាពមុខរបរវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស | | | |
| N | សកម្មភាពសេវាកម្មរដ្ឋបាល និងសេវាគាំទ្រ | | | |
| O | រដ្ឋបាលសាធារណៈ និងការការពារសន្តិសុខសង្គមចំបាច់ | | | |
| P | ការសិក្សាអប់រំ | | | |
| Q | សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គមកិច្ច | | | |
| R | សកម្មភាពសិល្បៈ គ្រឿងកំសាន្ត និងការកំសាន្ត | | | |
| S | សេវាកម្មដ៏ទៃទៀត | | | |
| T | សកម្មភាពម្ចាស់ការនិងផលិតសេវាកម្មគ្រួសារសំរាប់ | | | |
| U | ប្រើប្រាស់ខ្លួនឯងសកម្មភាពអង្គការនិងស្ថាប័នក្រៅដែនដី | | | |

បង្ហាញពីភាពគ្របដណ្តប់នៃជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១។

១) ចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចអន្តរជាតិ

ឧបសម្ព័ន្ធ៥

## ភាពគ្របដណ្តប់ នៃអង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤ និងការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជាឆ្នាំ ២០០៩

| (ផ្នែកនៃចំណាត់ថ្នាក់វិស័យ ស្តង់ដារអន្តរជាតិ Rev/4. ១) | | ប្រភេទសហគ្រាស | | |
|---|---|---|---|---|
| | | ទីតាំង ជាប់លាប់ | ទីតាំងជាប់លាប់ ប៉ុន្តែអាចរុះរើបាន | ទីតាំង ចល័ត |
| A | កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | | | |
| B | សកម្មភាពអាជីវកម្មរ៉ែ និងថ្ម | | | |
| C | សកម្មភាពផលិតកម្ម | | | |
| D | ការផ្គត់ផ្គង់អគ្គីសនី ឧស្ម័ន ចំហាយ និង ខ្យល់ត្រជាក់ | | | |
| E | ការផ្គត់ផ្គង់ទឹក ការងារគ្រប់គ្រងទឹកស្អុយ កាកសំណល់ និងការកែច្នៃកាកសំណល់ | | | |
| F | សំណង់ | | | |
| G | ការលក់ដុំ និងលក់រាយ ការជួសជុលយានយន្ត និងទោចក្រយានយន្ត | | | |
| H | ការដឹកជញ្ជូន និងស្តុកទុក | | | |
| I | សកម្មភាពខាងការស្នាក់នៅ និងសកម្មភាពសេវាផ្នែកចំណីអាហារ | | | |
| J | ផ្នែកព័ត៌មានវិទ្យា និងទំនាក់ទំនងទូរគមនាគមន៍ | | | |
| K | សកម្មភាពហិរញ្ញវត្ថុ និងការធានារ៉ាប់រង | | | |
| L | សកម្មភាពអចលនទ្រព្យ | | | |
| M | សកម្មភាពមុខរបរវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស | | | |
| N | សកម្មភាពសេវាកម្មរដ្ឋបាល និងសេវាគាំទ្រ | | | |
| O | រដ្ឋបាលសាធារណៈ និងការការពារសន្តិសុខសង្គមចំបាច់ | | | |
| P | ការសិក្សាអប់រំ | | | |
| Q | សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គមកិច្ច | | | |
| R | សកម្មភាពសិល្បៈ គ្រឿងកំសាន្ត និងការកំសាន្ត | | | |
| S | សេវាកម្មដ៏ទៃទៀត | | | |
| T | សកម្មភាពម្ចាស់ការនិងផលិតសេវាកម្មគ្រួសារសំរាប់ | | | |
| U | ប្រើប្រាស់ខ្លួនឯងសកម្មភាពអង្គការនិងស្ថាប័នក្រៅដែនដី | | | |

បង្ហាញពីភាពគ្របដណ្តប់នៃអង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ២០១៤ និង ការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជាឆ្នាំ ២០០៩

១) ចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចអន្តរជាតិ

# NIS

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងផែនការ
វិទ្យាស្ថានជាតិស្ថិតិ

From
the People of Japan

JICA